# ខ និងលក្ខខណ្ឌ
# កម្មវិធី ABA Mobile

កំណែ 2.2

មានសុពលភាពពីខែមីនា ឆ្នាំ2024

# មាតិកា


និយមន័យ ....2
សេចក្តីផ្តើម....5
1 ការពិពណ៌នាពីសេវាកម្ម....5
2 លក្ខខណ្ឌពេញសិទ្ធិរបស់អ្នកប្រើប្រាស់....5
3 ថ្លៃសេវា និងបន្ទុក....6
4 ការកម្រិតសេវាកម្ម ....6
5 សុវត្ថិភាព ....7
6 ការទទួលស្គាល់របស់អ្នកប្រើប្រាស់....9
7 កាតព្វកិច្ចរបស់អ្នក....10
8 ការទទួលខុសត្រូវ និងការសងសំណង ....10
9 វិវាទជាមួយពាណិជ្ជករ ឬអ្នកលក់....11
10 ការព្យួរ ឬការបញ្ឈប់កម្មវិធី ABA Mobile....11
11 លក្ខខណ្ឌឯកជនភាព ....12
12 លក្ខខណ្ឌជាក់លាក់បន្ថែម ....12
13 កម្មសិទ្ធិបញ្ញា ....12
14 វិសោធនកម្ម....12
15 ដំណោះស្រាយវិវាទ និងច្បាប់គ្រប់គ្រង....13
ឧបសម្ព័ន្ធ ក....13
ឧបសម្ព័ន្ធ ខ....15

# និយមន័យ

| | |
|---|---|
| ABA Mobile | មានន័យថាកម្មវិធីសម្រាប់ទូរស័ព្ទដែលអ្នកអាចដោនឡូតពី App Store ឬ Google Play បាន ។ |
| ABA Pay | មានន័យថាមុខងារទូទាត់តាមទូរស័ព្ទដែលអនុញ្ញាតឲ្យអ្នកប្រើកម្មវិធី ABA Mobile អាចធ្វើការទូទាត់ ឬទិញទំនិញនានាដោយប្រើគណនី ABA របស់ខ្លួន ឬភ្ជាប់ជាមួយកាត Visa/Mastercard នៅតាមហាង ឬពាណិជ្ជករអនឡាញនានាដោយស្កែនកូដ QR ដែលត្រូវគ្នានោះ ។ |
| ទីកន្លែង ABA Pay | មានន័យថា បញ្ជីទីកន្លែងលក់ រួមមានពាណិជ្ជកររូបវន្ត និងពាណិជ្ជករអនឡាញដែលទទួលការទូទាត់តាម ABA Pay ។ |
| គណនី | មានន័យថា និងរួមបញ្ចូលទាំងគណនីសន្សំ គណនីចរន្ត គណនីចរន្ត Plus គណនីបត់បែនប្រាក់រៀល ឬគណនីបញ្ញើមានកាលកំណត់របស់ធនាគារ ABA ទាំងរូបិយប័ណ្ណប្រាក់រៀល និងប្រាក់ដុល្លារ ដែលអាចបើកពីមួយពេលទៅមួយពេលនៅតាមសាខា ABA ឬតាមរយៈកម្មវិធី ABA Mobile ។ |
| ឧបករណ៍កំណត់អត្តសញ្ញាណតាមជីវមាត្រ (Biometric Identifier) | រួមមាន ស្នាមម្រាមដៃ ទិន្នន័យផ្ទៃមុខ និងមធ្យោបាយផ្សេងៗដែលក្រុមហ៊ុនផលិតឧបករណ៍ចល័តអនុញ្ញាតឲ្យអ្នកប្រើប្រាស់ផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ពួកគេសម្រាប់គោលបំណងបើកសោឧបករណ៍ចល័តរបស់ពួកគេ និងចូលប្រើប្រាស់កម្មវិធីមួយចំនួន រួមទាំងកម្មវិធី ABA Mobile ។ |
| CamDX | សំដៅលើថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ដែលបង្កើតឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយត្រូវបានប្រើប្រាស់សម្រាប់ការផ្ទៀងផ្ទាត់អត្តសញ្ញាណBប័ណ្ណសញ្ជាតិខ្មែរ អំឡុងពេលទទួលយកអតិថិជនថ្មីតាមកម្មវិធី ABA Mobile ។ |
| កាត | មានន័យថា និងរួមបញ្ចូលទាំងកាតឥណពន្ធ/ឥណទាន ABA ដែលមានបណ្តាញកាតទូទាត់ផ្សេងៗជាច្រើន ដូចជាកាត VISA/Mastercard/UPI ក្នុងទម្រង់ជាកាតនិម្មិត ឬកាតផ្លាស្ទីក ។ |
| លេខ CIF | លេខសម្គាល់អត្តសញ្ញាណអតិថិជននីមួយៗដែលប្រើប្រាស់នៅក្នុងប្រព័ន្ធធនាគារ ABA ដែលអ្នកទទួលអំឡុងពេលការចុះឈ្មោះគណនីដំបូងរបស់អ្នកជាមួយធនាគារ ABA ។ |
| មាតិកា | មានន័យថា និងរួមបញ្ចូលទាំងព័ត៌មាន រូបភាព លីង សំឡេង ក្រាហ្វិក វីដេអូ កម្មវិធី ឬឯកសារផ្សេងៗណាមួយ រួមមាន តារាងតម្លៃ ព័ត៌មាន និងទិន្នន័យការស្រាវជ្រាវដែលមានតាមរយៈកម្មវិធី ABA Mobile ។ |
| អតិថិជន | រួមមានម្ចាស់គណនី ABA និងមិនមែនម្ចាស់គណនី ABA ដែលបានប្រើប្រាស់សេវារបស់ធនាគារ ABA ម្តងម្កាល ។ អតិថិជនទាំងអស់ត្រូវទទួលការអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជនក្នុងទម្រង់ផ្សេងៗគ្នា ។ |
| E-cash | មានន័យថាសេវាដកប្រាក់ដោយមិនបាច់ប្រើកាតនៅតាម ATM ណាមួយរបស់ធនាគារ ABA ដោយប្រើលេខកូដដែលបង្កើតនៅក្នុងកម្មវិធី ABA Mobile ។ |
| របាយការណ៍អេឡិកត្រូនិក (e-Statement) | មានន័យថា របាយការណ៍សេវាធនាគាររួមគ្នាមួយដែលបង្ហាញពីកំណត់ត្រាធនាគារ ABA សម្រាប់រយៈពេលជាក់លាក់មួយសម្រាប់គណនីរបស់អតិថិជននៅក្នុងកម្មវិធី ABA Mobile ។ របាយការណ៍អេឡិកត្រូនិកនេះសម្រាប់តែគោលបំណងផ្តល់ជាព័ត៌មានប៉ុណ្ណោះ ។ |

| | |
|---|---|
| វិញ្ញាបនបត្របញ្ជាក់ពីបញ្ញើមានកាលកំណត់: | មានន័យថា ឯកសារអេឡិកត្រូនិកជាព័ត៌មាននៃគណនីបញ្ញើមានកាលកំណត់របស់អ្នកដែលបានបើកតាមរយៈកម្មវិធី ABA Mobile ឬនៅតាមសាខា ABA ។ |
| គណនីរហ័ស | ជាគណនីមួយប្រភេទរបស់ ABA ជាមួយមុខងារមានកម្រិតកំណត់ ដែលអតិថិជនថ្មី អាចបើកបានក្នុងកម្មវិធី ABA Mobile ដោយមិនបាច់ទៅធនាគារ។ |
| កែសំណុំដើម (Jailbreak ឬ Root) | មានន័យថា ទូរស័ព្ទ ឬ ឧបករណ៍ចល័តណាមួយ ត្រូវបានកែប្រែសំណុំដើមនៃប្រព័ន្ធដំណើរការ ដើម្បីដក ឬលុបរនាំងការពារ ដែលបង្កើតដោយរោងចក្រផលិត ឬ ប្រតិបត្តិករ ដែលបើកឲ្យមានការដំឡើងកម្មវិធីមិនសមស្រប ឬមិនត្រូវបានអនុញ្ញាត។ |
| អត្តសញ្ញាណអ្នកប្រើកម្មវិធី ABA Mobile (ABA Mobile ID) | មានន័យថាលេខកំណត់អត្តសញ្ញាណផ្ទាល់ដាច់ដោយឡែកដែលផ្តល់ឲ្យអ្នកប្រើប្រាស់កម្មវិធី ABA Mobile នីមួយៗអំឡុងពេលចុះឈ្មោះ។ |
| ប្រតិបត្តិករទូរស័ព្ទ | មានន័យថា ប្រតិបត្តិករបណ្តាញឬទូរស័ព្ទចល័តដែលចូលរួម។ |
| ការជូនដំណឹង | មានន័យថា និងរួមបញ្ចូលទាំងសារទូរស័ព្ទ និងការជូនដំណឹងក្នុងកម្មវិធីទូរស័ព្ទដែលផ្ញើឲ្យអ្នកក្នុងឱកាសផ្សេងៗគ្នាពាក់ព័ន្ធនឹងប្រតិបត្តិការធនាគារ ឬការផ្តល់សញ្ញាទូទៅដែលផ្ញើដោយធនាគារ ABA។ |
| ការទូទាត់ | មានន័យថា ការបង្គាប់ការទូទាត់ដែលអ្នកធ្វើឡើងតាមរយៈកម្មវិធី ABA Mobile ដើម្បីធ្វើការដកប្រាក់ចេញពីគណនីត្រឹមត្រូវរបស់អ្នកសម្រាប់ការទូទាត់ណាមួយ ឧទាហរណ៍ដើម្បីធ្វើការទូទាត់ឲ្យពាណិជ្ជករ។ |
| ព័ត៌មានផ្ទាល់ខ្លួន | សំដៅលើព័ត៌មានផ្ទាល់ខ្លួនដែលអ្នកផ្តល់ឲ្យធនាគារ ABA រួមមានជាអាទិ៍ ឈ្មោះ លេខអត្តសញ្ញាណប័ណ្ណ (NID) ថ្ងៃខែឆ្នាំកំណើត លេខទូរស័ព្ទ អ៊ីមែល អាសយដ្ឋាន។ |
| លេខសម្ងាត់ (PIN) | មានន័យថា លេខសម្ងាត់ 4 (បួន) ខ្ទង់ដោយឡែកពីគ្នាសម្រាប់ប្រើប្រាស់កម្មវិធី ABA Mobile និងសម្រាប់បញ្ជាក់ពីប្រតិបត្តិការណាមួយ។ |
| កាតផ្លាស្ទិក | មានន័យថាកាតឥណពន្ធ/ឥណទាន VISA, Mastercard ឬ UPI រូបវន្តដែលចេញដោយធនាគារ ABA ឬតាមរយៈកម្មវិធី ABA Mobile ។ |
| ក្រុមហ៊ុនផ្តល់សេវាទូទាត់ (PSP) | សំដៅលើនីតិបុគ្គលស្របច្បាប់ដែលត្រូវបានផ្តល់អាជ្ញាប័ណ្ណដោយធនាគារជាតិនៃកម្ពុជា (NBC) ដើម្បីធ្វើប្រតិបត្តិការសេវាហិរញ្ញវត្ថុនៅក្នុងកម្ពុជា និងត្រូវបានអនុម័តដោយធនាគារ ABA សម្រាប់ការភ្ជាប់សេវាកម្មនានា ដូចជាសេវាទូទាត់ ឬផ្ទេរប្រាក់ដែលស្ថិតក្រោមការរៀបចំស្របច្បាប់មួយចំនួន។ |
| ស្កេន QR | មានន័យថា សេវាស្កេនកូដ QR នៅក្នុងកម្មវិធី ABA Mobile ដែលអនុញ្ញាតឲ្យអ្នកប្រើប្រាស់អាចស្កេនដើម្បីទូទាត់នៅតាមទីកន្លែងលក់ដែលអនុញ្ញាត ABA Pay ឬដើម្បីស្កេនកូដ QR នៅតាមទីកន្លែងផ្សេងៗរបស់ធនាគារ ABA ដើម្បីដំណើរការប្រតិបត្តិការប្រភេទផ្សេងៗជាច្រើន។ |
| ពាក្យសម្ងាត់ | មានន័យថា ជាពាក្យអាចចាំបាន ដែលអ្នកត្រូវបង្កើតឡើងដោយខ្លួនឯង ដើម្បីជាផ្នែកមួយនៃព័ត៌មានសម្ងាត់សម្រាប់ ABA Mobile របស់អ្នក។ ពាក្យសម្ងាត់នេះ ត្រូវប្រើដើម្បីបញ្ជាក់អត្តសញ្ញាណរបស់អ្នក នៅពេលអ្នកបើកដំណើរការ ABA Mobile ឡើងវិញ, ធ្វើប្រតិបត្តិការក្នុងចំនួនទឹកប្រាក់ច្រើន, ធ្វើការផ្លាស់ប្តូរអ្វីមួយនៅកន្លែង ការកំណត់ផ្សេងៗ ។ល។ ពាក្យសម្ងាត់នេះ ត្រូវរក្សាទុកជាសម្ងាត់ ដោយមិនត្រូវបង្ហាញ ឬប្រាប់ឲ្យអ្នកណាម្នាក់ដឹងឡើយ រួមទាំងបុគ្គលិករបស់ ABA ផងដែរ។ |

| | |
|---|---|
| អត្តសញ្ញាណសុវត្ថិភាព | មានន័យថា និងរួមបញ្ចូលទាំងពាក្យសម្ងាត់ លេខអត្តសញ្ញាណផ្ទាល់ខ្លួន ឬចូលប្រើប្រាស់ លេខសម្ងាត់(PIN) ប្រើតែមួយដង (OTP) និងលេខកូដ និងនីតិវិធីចូលប្រើប្រាស់ផ្សេងៗ រួមមានសេវាផ្ញើសារ SMS សម្រាប់ការចូលប្រើប្រាស់ ឬការប្រើប្រាស់សេវាកម្មនានានៅក្នុងកម្មវិធី ABA Mobile ដែលយើងផ្តល់ឲ្យពីមួយពេលទៅមួយពេល។ |
| អ្នកផ្តល់សេវាកម្មតតិយភាគី | មានន័យថា និងចង្អុលបង្ហាញបុគ្គលណាមួយ (រូបវន្តបុគ្គល ឬនីតិបុគ្គល) ដែលធនាគារ ABA មានទំនាក់ទំនងជាមួយសម្រាប់ការចែកចាយសេវាកម្មដោយផ្ទាល់តាមរយៈកម្មវិធី ABA Mobile ឬតាមរយៈវិបសាយ ឬកម្មវិធីរបស់តតិយភាគី។ |
| ការផ្ទេរប្រាក់ | សំដៅលើការផ្ទេរប្រាក់ដែលធនាគារ ABA ក្លាយជាធនាគារទូទាត់ ឬទទួលប្រាក់តាងនាមឲ្យអ្នក ដើម្បីអនុវត្តតាមសំណើទូទាត់ទៅកាន់អ្នក ឬពីអ្នកប្រកបដោយប្រសិទ្ធភាព។ ការផ្ទេរប្រាក់រួមមានទាំងការផ្ទេរប្រាក់ក្នុងធនាគារ និងរវាងធនាគារ ឧទាហរណ៍ ការផ្ទេរប្រាក់ពីអ្នកទៅកាន់អ្នកទទួលផ្សេងទៀតនៅក្នុងធនាគារ ABA ឬអ្នកទទួលនៅក្នុងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេង ដូចជាធនាគារ ឬអ្នកផ្តល់សេវាទូទាត់ផ្សេងៗ។ |
| ប្រតិបត្តិការ | មានន័យថា កំណត់ត្រា ឬប្រតិបត្តិការហិរញ្ញវត្ថុណាមួយដែលអ្នក ឬបុគ្គលណាមួយអះអាងថាជាអ្នក ឬបុគ្គលណាមួយ តាមនាមឲ្យអ្នកដោយមាន ឬគ្មានការយល់ព្រមពីអ្នកក៏ដោយ ធ្វើឡើង អនុវត្តដំណើរការ ឬធ្វើឲ្យមានប្រសិទ្ធភាពនោះ រួមមាន<br>▪ ការទូទាត់ណាមួយ ឬការផ្ទេរប្រាក់មក/ពីគណនីរបស់អ្នក<br>▪ ប្រតិបត្តិការធនាគារផ្សេងៗណាមួយដែលអាចមានតាមរយៈធនាគារ ABA ពីមួយពេលទៅមួយពេល (រួមមានការទូទាត់វិក្កយបត្រ) និង<br>▪ ប្រតិបត្តិការធនាគារណាមួយដែលធ្វើឡើងតាមរយៈសាខា ABA ណាមួយ |
| ប្រវត្តិប្រតិបត្តិការ | ចង្អុលបង្ហាញពីបញ្ជីប្រតិបត្តិការទាំងអស់ដែលបានចុះហត្ថលេខា ឬធ្វើឡើងនៅក្នុងគណនី ABA ក្នុងរយៈពេលជាក់លាក់មួយ។ |
| ឈ្មោះបើកចូល | ការកំណត់អត្តសញ្ញាណរបស់អ្នកសម្រាប់ការចូលប្រើប្រាស់កម្មវិធី ABA Mobile។ វាត្រូវការចាំបាច់សម្រាប់បង្កើតនៅពេលបើកដំណើរការលើកដំបូង និងចងចាំសម្រាប់ការប្រើប្រាស់លើកក្រោយៗ។ |
| ពាណិជ្ជករ | មានន័យថា អ្នកផ្តល់សេវាកម្មតតិយភាគីដែលបង្កើតទំនាក់ទំនងជាមួយធនាគារ ABA ដែលធ្វើការទូទាត់ឲ្យពាណិជ្ជករចេញពីគណនីរបស់អ្នកដោយប្រើកម្មវិធី ABA Mobile។ |
| កាតនិម្មិត | មានន័យថា កាតឥណពន្ធ VISA ឬ Mastercard ដែលបង្កើតឡើងតាមរយៈកម្មវិធី ABA Mobile។ |
| 'យើង', 'យើងខ្ញុំ', 'របស់យើង', 'របស់យើងខ្ញុំ' | សំដៅលើធនាគារ វឌ្ឍនៈអាស៊ី ចំកាត់។ |
| 'អ្នក', 'របស់អ្នក, 'របស់លោកអ្នក' | សំដៅលើម្ចាស់គណនី និងអ្នកប្រើប្រាស់កម្មវិធី ABA Mobile។ |

# សេចក្តីផ្តើម

លក្ខខណ្ឌទាំងនេះ (“លក្ខខណ្ឌជាក់លាក់”) គ្រប់គ្រងការប្រើប្រាស់កម្មវិធីសេវាធនាគារតាមទូរស័ព្ទរបស់ធនាគារ ABA ដែលមានឈ្មោះថា “ABA Mobile”។ សម្រាប់អ្នកប្រើប្រាស់កម្មវិធី ABA Mobile វាមានសារៈសំខាន់ណាស់ដែលអ្នកត្រូវអានលក្ខខណ្ឌជាក់លាក់ឲ្យបានយល់ច្បាស់។ តាមរយៈការចុះឈ្មោះ និងប្រើប្រាស់ ABA Mobile មានន័យថាអ្នកយល់ព្រមអនុលោមតាមលក្ខខណ្ឌជាក់លាក់នេះ។

ដោយចុច “យល់ព្រម”អ្នកបញ្ជាក់ថា អ្នកកំពុងធ្វើសកម្មភាពដោយខ្លួនរបស់អ្នកផ្ទាល់ មិនមែនក្នុងនាមជាអ្នកទីបីទេ ហើយអ្នកបានអាន យល់ ទទួលស្គាល់ ទទួលយក និងផ្តល់ការយល់ព្រមច្បាស់លាស់របស់អ្នកចំពោះលក្ខខណ្ឌជាក់លាក់នេះ។

សូមកត់សម្គាល់ផងដែរថា លក្ខខណ្ឌជាលាយលក្ខណ៍អក្សរផ្សេងណាមួយដែលពាក់ព័ន្ធនឹងសេវាកម្ម និងគណនី ABA របស់អ្នកនឹងបន្តអនុវត្ត។ ក្នុងកម្រិតដែលលក្ខខណ្ឌផ្សេងមិនត្រូវគ្នានឹងលក្ខខណ្ឌជាក់លាក់ នោះលក្ខខណ្ឌជាក់លាក់នឹងត្រូវយកជាការ (លុះត្រាតែមានលក្ខខណ្ឌផ្សេងណាត្រូវបានបញ្ជាក់ច្បាស់លាស់ឲ្យអនុវត្តជំនួសលក្ខខណ្ឌជាក់លាក់នោះ)។

## 1 ការពិពណ៌នាពីសេវាកម្ម

**1.1** កម្មវិធី ABA Mobile ប្រើប្រាស់បណ្តាញទូរគមនាគមន៍របស់ប្រតិបត្តិករទូរស័ព្ទចល័តដែលចូលរួម ("ប្រតិបត្តិករទូរស័ព្ទ")។ កម្មវិធី ABA Mobile អនុញ្ញាតឲ្យអ្នកអាចចូលប្រើប្រាស់គណនីរបស់ខ្លួន និងសេវាធនាគារមួយចំនួនដែលមាននៅក្នុងកម្មវិធី ABA Mobile ពីមួយពេលទៅមួយពេលក្នុងទម្រង់ដែលងាយស្រួលជាងក្នុងការមើល និងធ្វើឲ្យប្រតិបត្តិការលើទូរស័ព្ទរបស់អ្នកមានប្រសិទ្ធភាព។

**1.2** សម្រាប់ព័ត៌មានលម្អិតអំពីកម្មវិធី ABA Mobile សូមយោងលើសំណួរសួរញឹកញាប់ដែលមាននៅលើវិបសាយ www.ababank.com/aba-mobile ។

**1.3** មុខងារសំខាន់ៗរបស់កម្មវិធី ABA Mobile រួមមាន៖

- ក. ពិនិត្យមើលសមតុល្យគណនីរបស់អ្នក
- ខ. ពិនិត្យមើលព័ត៌មានលម្អិតអំពីប្រតិបត្តិការទាំងអស់របស់អ្នក
- គ. ផ្ទេរការផ្ទេរប្រាក់ក្នុងស្រុក និងអន្តរជាតិ
- ឃ. ទូទាត់វិក្កយបត្រ
- ង. ដោនឡូតរបាយការណ៍អេឡិកត្រូនិក
- ច. បង្កើតកាតនិម្មិតឥណពន្ធ Visa/Mastercard
- ឆ. ផ្ញើប្រាក់ទៅ ATM ដោយប្រើសេវា E-Cash
- ជ. បើកគណនី ABA ថ្មី
- ឈ. ទូទាត់ឲ្យពាណិជ្ជកររូបវន្ត ឬអនឡាញជាមួយ ABA Pay
- ញ. សម្រាប់ព័ត៌មានលម្អិតអំពីមុខងារ និងសេវាកម្មរបស់កម្មវិធី ABA Mobile សូមមើលឧបសម្ព័ន្ធ ក ។

## 2 លក្ខខណ្ឌពេញសិទ្ធិរបស់អ្នកប្រើប្រាស់

**2.1** អ្នកម្ចាស់គណនី ABA

**2.2** អ្នកម្ចាស់គណនី ABA

**2.3** អ្នកមានទូរស័ព្ទ/ឧបករណ៍ដែលមានលក្ខខណ្ឌពេញសិទ្ធិ

**2.4** អ្នកមានលេខទូរស័ព្ទដែលមានសុពលភាព និងកំពុងដំណើរការ

**2.5** អ្នកបានដំឡើងកម្មវិធី ABA Mobile នៅលើឧបករណ៍របស់អ្នកដោយប្រើលេខទូរស័ព្ទមានសុពលភាពរបស់អ្នកដែលបានចុះឈ្មោះពេលបើកគណនីជាមួយធនាគារ ABA ។

**2.6** អ្នកបានទទួលស្គាល់ថា ធនាគារ ABA រក្សាសិទ្ធិក្នុងការបដិសេធសំណើសុំបើកដំណើរការកម្មវិធី ABA Mobile របស់អ្នក ដោយមិនមានផ្តល់មូលហេតុណាមួយអំឡុងពេលបើកដំណើរការកម្មវិធី។

# 3 ថ្លៃសេវា និងបន្ទុក

**3.1** កម្មវិធី ABA Mobile អាចប្រើប្រាស់បានដោយឥតគិតថ្លៃ។ ប៉ុន្តែ ថ្លៃសេវា និងបន្ទុកអាចអនុវត្តនៅពេលអ្នកធ្វើប្រតិបត្តិការមួយចំនួន ឬប្រើប្រាស់ផលិតផល ឬសេវាកម្មជាក់លាក់ដែលមានក្នុងកម្មវិធី ABA Mobile ដោយអនុលោមតាមលក្ខខណ្ឌជាក់លាក់។ អ្នកផ្តល់សិទ្ធិឲ្យធនាគារ ABA ដកប្រាក់ចេញពីគណនីរបស់អ្នកនូវថ្លៃសេវា និងបន្ទុកដែលអនុវត្តទាំងអស់នោះដូចមានរៀបរាប់នៅក្នុងលក្ខខណ្ឌជាក់លាក់។ ធនាគារ ABA អាចដាក់ឲ្យប្រើប្រាស់នូវថ្លៃសេវា និងបន្ទុកបន្ថែមនានាសម្រាប់ការប្រើប្រាស់កម្មវិធី ABA Mobile របស់អ្នកពីមួយពេលទៅមួយពេល ហើយធនាគារ ABA ក៏អាចផ្លាស់ប្តូរថ្លៃសេវា និងបន្ទុកនានាពីមួយពេលទៅមួយពេលដែរ។ ព័ត៌មានលម្អិតអំពីថ្លៃសេវា និងបន្ទុកនាពេលបច្ចុប្បន្នរបស់ធនាគារ ABA មាននៅតាមសាខា ឬនៅលើវិបសាយរបស់ធនាគារ ABA https://www.ababank.com ។ មុនពេលធ្វើប្រតិបត្តិការណាមួយ អ្នកយល់ព្រមពិនិត្យថ្លៃសេវា និងបន្ទុកនាពេលបច្ចុប្បន្ន ហើយអ្នកយល់ព្រមទទួលយកថ្លៃសេវា និងបន្ទុកដោយធ្វើប្រតិបត្តិការ។

**3.2** អ្នកអាចទទួលទូទាត់បន្ទុកជូនក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទសម្រាប់ការដោនឡូត ធ្វើបច្ចុប្បន្នភាព និងប្រើប្រាស់កម្មវិធី ABA Mobile។ បន្ទុកណាមួយជាការទទួលខុសត្រូវរបស់អ្នកតែម្នាក់បុណ្ណោះ ហើយបញ្ហានានាពាក់ព័ន្ធនឹងបន្ទុកគួរតែលើកឡើងជាមួយប្រតិបត្តិករទូរស័ព្ទ។ អ្នកគួរតែទាក់ទងប្រតិបត្តិករទូរស័ព្ទសម្រាប់ព័ត៌មានបន្ថែមអំពីថ្លៃសេវា និងបន្ទុកនានារបស់ពួកគេ។

# 4 ការកម្រិតសេវាកម្ម

## 4.1 កម្រិតប្រតិបត្តិការ

**4.1.1** ជាផ្នែកមួយនៃវិធានការកាត់បន្ថយហានិភ័យជាប្រចាំ ធនាគារ ABA រក្សាសិទ្ធិក្នុងការកំណត់ និងផ្លាស់ប្តូរការកម្រិតចំនួនទឹកប្រាក់ប្រតិបត្តិការ លក្ខខណ្ឌ ព្រមទាំងគោលដៅការផ្ទេរប្រាក់ និងបញ្ហាផ្សេងៗគ្រប់ពេលវេលា ដោយមិនជម្រាបជូនដំណឹងជាមុន។ សម្រាប់ព័ត៌មានលម្អិតអំពីកម្រិតប្រតិបត្តិការ សូមមើលឧបសម្ព័ន្ធ ខ។

## 4.2 កម្រិតការចូលប្រើប្រាស់

**4.2.1** ដើម្បីបង្ការហានិភ័យដែលអាចកើតមានណាមួយ អ្នកនឹងមិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់កម្មវិធី ABA Mobile ក្នុងស្ថានភាពដូចខាងក្រោម៖

ក. អ្នកប៉ុនប៉ងថត ឬថតអេក្រង់ (screenshot) ខណៈពេលកម្មវិធី ABA Mobile កំពុងដំណើរការលើឧបករណ៍។

ខ. ឧបករណ៍របស់អ្នកត្រូវបានផលិតសម្រាប់ប្រទេសជាក់លាក់មួយដែលការកំណត់ជាក់លាក់របស់ប្រព័ន្ធប្រតិបត្តិការពិសេសណាមួយដែលមិនត្រូវគ្នាជាមួយនឹងស្តង់ដារអន្តរជាតិ។

## 4.3 ការតភ្ជាប់

**4.3.1** ធនាគារ ABA មិនទទួលខុសត្រូវចំពោះអតិថិជនសម្រាប់ភាពមិនពេញលេញ អវត្តមានភាពសម្រាប់ប្រើប្រាស់ ការខកខាន ការរំខាន ការព្យួរ ឬការពន្យារណាមួយនៅក្នុងកម្មវិធី ABA Mobile ឡើយ (រួមមាន ការបញ្ជូនការផ្តល់សញ្ញា ឬការផ្តល់ដំណឹងណាមួយ ឬការទទួល ឬការអនុវត្តនូវការណែនាំណាមួយ) ដោយសារកត្តាណាមួយដែលមិនស្ថិតក្រោមការគ្រប់គ្រងសមស្របរបស់ធនាគារ ABA។ សូមយោងលើប្រការ 9 សម្រាប់ព័ត៌មានបន្ថែមអំពីកម្រិតនៃការទទួលខុសត្រូវរបស់ធនាគារ ABA។

## 4.4 ការថែរក្សាប្រព័ន្ធ

**4.4.1** ធនាគារ ABA អាចបន្ថែម ឬផ្អាកមុខងារណាមួយ ឬព្យួរប្រតិបត្តិការកម្មវិធី ABA Mobile ឬសេវាកម្មណាមួយរបស់ខ្លួននៅគ្រប់ពេលវេលា៖

ក. តាមការយល់ឃើញរបស់ធនាគារ ABA ប្រសិនបើមានការគំរាមកំហែងណាមួយចំពោះប្រព័ន្ធណាមួយពាក់ព័ន្ធនឹងកម្មវិធី ABA Mobile ឬផ្នែកណាមួយនៃប្រព័ន្ធ ឬ

ខ. សម្រាប់គោលបំណងអនុវត្តការថែទាំជាប្រចាំ និងការងាររដ្ឋបាល។

**4.4.2** ABA Mobile ជាកម្មវិធីវិវឌ្ឍជាប្រចាំដែលនឹងមានការបញ្ចេញជំនាន់ថ្មីជាញឹកញាប់ដើម្បីនាំមកនូវមុខងារ និងការអភិវឌ្ឍថ្មី ព្រមទាំងការធ្វើបច្ចុប្បន្នភាពប្រព័ន្ធប្រតិបត្តិការផងដែរ។ អ្នកត្រូវធ្វើបច្ចុប្បន្នភាព និងប្រើប្រាស់ជំនាន់នៃកម្មវិធី ABA Mobile ដែលមានបច្ចុប្បន្នភាពបំផុត។

**4.4.3** ពីមួយពេលទៅមួយពេល ធនាគារ ABA អាចបង្ខំឲ្យអ្នកប្រើប្រាស់កម្មវិធីធ្វើបច្ចុប្បន្នភាពកម្មវិធី ABA Mobile មកជំនាន់ចុងក្រោយបង្អស់ ដើម្បីសុវត្ថិភាព និងដំណើរការត្រូវគ្នា។ អ្នកមិនអាចបន្តប្រើប្រាស់ជំនាន់កម្មវិធី ABA Mobile ចាស់ៗបានទេ លុះត្រាតែអ្នកធ្វើបច្ចុប្បន្នភាពមកជំនាន់ចុងក្រោយបង្អស់។

# 5 សុវត្ថិភាព

## 5.1 ការប្រុងប្រយ័ត្នជាមុនទូទៅ

5.1.1 អ្នកត្រូវទទួលខុសត្រូវចំពោះ និងប្រើប្រាស់កិច្ចប្រឹងប្រែងខ្ពស់បំផុតដើម្បីបង្ការការប្រើប្រាស់ និងការចូលប្រើប្រាស់ដោយគ្មានការអនុញ្ញាតណាមួយនូវកម្មវិធី ABA Mobile នៅលើទូរស័ព្ទ និង/ឬឧបករណ៍នានារបស់អ្នក និងដើម្បីការពារព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក និងអត្តសញ្ញាណសុវត្ថិភាពនានាគ្រប់ពេលវេលា។ ឧទាហរណ៍ អ្នក៖

ក. មិនត្រូវអនុញ្ញាតឲ្យអ្នកផ្សេងប្រើប្រាស់អត្តសញ្ញាណសុវត្ថិភាពរបស់អ្នកដើម្បីចូលប្រើប្រាស់គណនីរបស់អ្នក ឬកម្មវិធី ABA Mobile នៅលើឧបករណ៍ចល័ត/ទូរស័ព្ទដៃរបស់អ្នក

ខ. មិនត្រូវអនុញ្ញាតឲ្យអ្នកផ្សេងណាមួយបើកសោឧបករណ៍ចល័ត/ទូរស័ព្ទដៃរបស់អ្នក ឬរក្សាឧបករណ៍កំណត់អត្តសញ្ញាណតាមជីវមាត្រ (Biometric Identifier) របស់ពួកគេនៅលើកម្មវិធី ABA Mobile និង/ឬ

គ. មិនត្រូវទុកឧបករណ៍ចល័ត/ទូរស័ព្ទដៃរបស់អ្នកចោលមិនមានមើលថែ ខណៈពេលអ្នកនៅតែប្រើប្រាស់គណនីរបស់អ្នក ឬកម្មវិធី ABA Mobile ។

ឃ. ធានាថា អត្តសញ្ញាណសុវត្ថិភាពរបស់អ្នកសម្រាប់ចូលប្រើប្រាស់កម្មវិធី ABA Mobile នៅរក្សាការសម្ងាត់ចំពោះតែអ្នកម្នាក់គត់ និងធានាថាអ្នកចាត់វិធានការសមស្របទាំងអស់ក្នុងការការពារអត្តសញ្ញាណទាំងនោះកុំឲ្យបង្ហាញនរណាម្នាក់ឡើយ។ ឧទាហរណ៍ អ្នកត្រូវ៖ ចងចាំអត្តសញ្ញាណសុវត្ថិភាពរបស់អ្នក មិនត្រូវសរសេរ ឬរក្សាអត្តសញ្ញាណសុវត្ថិភាពរបស់អ្នកនៅកន្លែងណាមួយជាទម្រង់ណាមួយ រួមមានជាអេឡិកត្រូនិក ឧទាហរណ៍ ក្នុងទូរស័ព្ទ ឬឧបករណ៍

ង. មិនត្រូវបង្ហាញអត្តសញ្ញាណសុវត្ថិភាពរបស់អ្នកទៅនរណាម្នាក់ (រួមមាន ប៉ូលីស បុគ្គលិកធនាគារ ឬអ្នកជាទីស្រលាញ់របស់អ្នក)

ច. ប្រុងប្រយ័ត្នដើម្បីធានាថា មិនមាននរណាម្នាក់អាចឃើញអ្នកបញ្ចូលអត្តសញ្ញាណសុវត្ថិភាពរបស់អ្នកឡើយ និង/ឬ

ឆ. មិនត្រូវតម្លើង ឬ ប្រើកម្មវិធី ABA Mobile លើឧបករណ៍ចល័ត/ទូរស័ព្ទដៃដែលត្រូវបានកែសំណុំដើម (jailbroken or rooted)។

5.1.2 អ្នកត្រូវចាក់សោឧបករណ៍ចល័តរបស់អ្នក ឬចាត់វិធានការចាំបាច់ផ្សេងៗដើម្បីបញ្ឈប់ការប្រើប្រាស់កម្មវិធី ABA Mobile ដោយគ្មានការអនុញ្ញាត។

5.1.3 អ្នកត្រូវជូនដំណឹងមក ABA ភ្លាមៗ ដោយទាក់ទងមកកាន់លេខ 1800 203 203 នៅពេលដឹងថា៖

ក. ឧបករណ៍ចល័ត/ទូរស័ព្ទដៃរបស់អ្នកបានបាត់ ឬត្រូវបានគេលួចបាត់

ខ. លេខសម្ងាត់ (PIN) របស់អ្នកត្រូវបានគេដឹង ឬអាចត្រូវបានអ្នកផ្សេងដឹង

គ. ពាក្យសម្ងាត់ (Secret Word) របស់អ្នកត្រូវបានគេដឹង ឬអាចត្រូវបានអ្នកផ្សេងដឹង

ឃ. អ្នកផ្សេងអាចបើកសោឧបករណ៍ចល័ត/ទូរស័ព្ទដៃរបស់អ្នក និង/ឬរក្សាស្នាមម្រាមដៃរបស់ពួកគេ និងឧបករណ៍កំណត់អត្តសញ្ញាណតាមជីវមាត្រ (Biometric Identifier) នៅលើទូរស័ព្ទដៃរបស់អ្នក ប្រសិនបើអ្នកអនុញ្ញាតឲ្យមានការកំណត់អត្តសញ្ញាណស្នាមម្រាមដៃនៅលើកម្មវិធី ABA Mobile ឬ

ង. មានការចូលប្រើប្រាស់គណនីរបស់អ្នកដោយគ្មានការអនុញ្ញាត តាមរយៈកម្មវិធី ABA Mobile។

ច. អ្នកកត់សម្គាល់ថា កម្មវិធី ABA Mobile កំពុងស្នើសុំឲ្យអ្នកបើកដំណើរការឡើងវិញនូវកម្មវិធីនេះ (ដែលអាចបង្ហាញថា កម្មវិធី ABA Mobile កំពុងបើកដំណើរការដោយប្រើអត្តសញ្ញាណសុវត្ថិភាពរបស់អ្នកនៅលើឧបករណ៍ផ្សេងទៀត)។

5.1.4 អ្នកត្រូវដំឡើងតែកម្មវិធីដែលបានអនុម័តនៅលើឧបករណ៍ចល័តរបស់អ្នក ហើយអ្នកមិនត្រូវកែប្រែសំណុំដើមលើឧបករណ៍ចល័តរបស់អ្នក (ឧ. jailbreak ឬ root ឧបករណ៍ចល័តរបស់អ្នក)។

5.1.5 អ្នកត្រូវធ្វើបច្ចុប្បន្នភាពភ្លាមៗ និងនៅរក្សាឲ្យទាន់បច្ចុប្បន្នភាពនូវប្រព័ន្ធប្រតិបត្តិការ និងកម្មវិធីសុវត្ថិភាពសម្រាប់ឧបករណ៍ចល័ត/ទូរស័ព្ទដៃរបស់អ្នកនៅពេលក្រុមហ៊ុនផលិតឧបករណ៍ចល័ត/ទូរស័ព្ទដៃរបស់អ្នក ឬក្រុមហ៊ុនផ្តល់ប្រព័ន្ធប្រតិបត្តិការឧបករណ៍ចល័ត/ទូរស័ព្ទដៃរបស់អ្នកបញ្ចេញកម្មវិធីសុវត្ថិភាពនោះ។

5.1.6 អ្នកមិនត្រូវអនុញ្ញាតឲ្យអ្នកផ្សេងណាមួយរក្សាទុកឧបករណ៍កំណត់អត្តសញ្ញាណតាមជីវមាត្រ (Biometric Identifier) នៅលើឧបករណ៍ចល័ត/ទូរស័ព្ទដៃរបស់អ្នក។

5.1.7 មុនពេលអ្នកលក់ឲ្យ ឬឲ្យឧបករណ៍ចល័ត/ទូរស័ព្ទដៃរបស់អ្នកទៅនរណាម្នាក់ អ្នកត្រូវលុបចោលកម្មវិធី ABA Mobile និងឧបករណ៍កំណត់អត្តសញ្ញាណតាមជីវមាត្រ ( Biometric Identifier) របស់អ្នកទាំងអស់ (ឧ.TouchID ឬ FaceID) ដែលបានចុះឈ្មោះក្នុងឧបករណ៍។

## 5.2 .អត្តសញ្ញាណសុវត្ថិភាព

5.2.1 កម្មវិធី ABA Mobile និងសេវាកម្មរបស់កម្មវិធីនេះតម្រូវឲ្យប្រើប្រាស់អត្តសញ្ញាណសុវត្ថិភាពដែលមានឈ្មោះអ្នកប្រើប្រាស់ និងលេខកូដ PIN 4 ខ្ទង់។

5.2.2 អំឡុងពេលបើកដំណើរការដំបូងនូវកម្មវិធី ABA Mobile អ្នកត្រូវបង្កើតពាក្យសម្ងាត់ និងលេខសម្ងាត់ (PIN) 4 ខ្ទង់ ដែលមានសុវត្ថិភាព និងអាចចងចាំបានដែលនឹងត្រូវប្រើប្រាស់ដើម្បីបើកចូលប្រើប្រាស់កម្មវិធី ABA Mobile ។

5.2.3 ពាក្យសម្ងាត់ ត្រូវតែមិនអាចងាយស្មាន ហើយត្រូវមានលក្ខណៈដូចខាងក្រោម៖

ក. ត្រូវតែជាអក្សរក្រមលេខ

ខ. ត្រូវតែនៅចន្លោះពី 5 ទៅ 20តួ

គ. មិនត្រូវមានលាយឈ្មោះ ឬត្រកូលរបស់អ្នក

ឃ. អាចជាភាសាខ្មែរ ឬអង់គ្លេស

5.2.4 លើសពីនេះ អ្នកគួរពិចារណាប្រើប្រាស់លេខកូដផ្សេងៗគ្នាសម្រាប់បើកសោឧបករណ៍ចល័ត/ទូរស័ព្ទដៃរបស់អ្នក និងកាត សេវាធនាគារ ឬឧបករណ៍ផ្សេងៗ។ យើងណែនាំឲ្យអ្នកផ្លាស់ប្តូរលេខសម្ងាត់ (PIN) សុវត្ថិភាពរបស់អ្នកឲ្យបានទៀងទាត់។

5.2.5 លក្ខខណ្ឌតម្រូវសម្រាប់ម្ចាស់គណនីរួមគ្នា៖

ក. ម្ចាស់គណនី ABA រួមគ្នាដែលប្រើប្រាស់កម្មវិធី ABA Mobile មិនត្រូវបានអនុញ្ញាតឲ្យចែករំលែកលេខសម្ងាត់ (PIN) កម្មវិធី ABA Mobile ឡើយ។ ប្រសិនបើម្ចាស់គណនីរួមគ្នានីមួយៗមានបំណងប្រើប្រាស់កម្មវិធី ABA Mobile នោះអ្នកនីមួយៗត្រូវតែមានលេខ CIF ផ្ទាល់ខ្លួនរបស់ពួកគេ (ព័ត៌មានអតិថិជន) ហើយចុះឈ្មោះដាច់ដោយឡែកពីគ្នាសម្រាប់កម្មវិធី ABA Mobile។

ខ. ម្ចាស់គណនីរួមគ្នាអាចប្រើប្រាស់កម្រងព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេដោយមានព័ត៌មានលម្អិតគណនីរួមគ្នាដើម្បីបើកដំណើរការកម្មវិធី ABA Mobile។ សិទ្ធិចូលប្រើប្រាស់គណនីរួមគ្នានឹងអនុវត្តតាមលក្ខខណ្ឌគណនីរួមគ្នា។

## 5.3 វិធីផ្ទៀងផ្ទាត់ភាពត្រឹមត្រូវសម្រាប់បើកចូល និងសិទ្ធអនុញ្ញាត ក្នុង ABA Mobile

5.3.1 អ្នកជាអ្នកប្រើប្រាស់អាចជ្រើសរើសវិធីដែលអ្នកចូលចិត្តដើម្បីបើកចូលប្រើ ABA Mobile និងដើម្បីបញ្ជាក់ឬផ្តល់សិទ្ធិប្រតិបត្តិការធនាគាររួមមាន៖

ក. ប្រើកូដ PIN ឬពាក្យសម្ងាត់ ឬជីវមាត្រដើម្បីចូលប្រើ ABA Mobile

ខ. ប្រើកូដ PIN ឬពាក្យសម្ងាត់ ឬជីវមាត្រដើម្បីបញ្ជាក់ឬអនុញ្ញាតប្រតិបត្តិការធនាគារ។ វិធីសាស្ត្រនីមួយៗនឹងអនុវត្តតាមល័ក្ខខ័ណ្ឌរបស់វារួមទាំងប៉ុន្តែមិនកំណត់ចំពោះដែនកំណត់ប្រតិបត្តិការអប្បបរមានិងអតិបរមា។

5.3.2 5.3.2.ដោយអ្នក ជាអ្នកប្រើប្រាស់ឧបករណ៍ចល័ត/ទូរស័ព្ទដៃដែលមានលក្ខខណ្ឌពេញសិទ្ធិ អ្នកអាចជ្រើសរើសអនុញ្ញាតការផ្ទៀងផ្ទាត់ជីវមាត្រដើម្បីបើកចូលប្រើប្រាស់កម្មវិធី ABA Mobile ដោយប្រើឧបករណ៍កំណត់អត្តសញ្ញាណតាមជីវមាត្រ (Biometric Identifier) ដែលបានចុះឈ្មោះនៅលើឧបករណ៍ចល័ត/ទូរស័ព្ទដៃរបស់ខ្លួន។ កម្មវិធី ABA Mobile មិនប្រមូល ឬរក្សាទុកឧបករណ៍កំណត់អត្តសញ្ញាណតាមជីវមាត្រ (Biometric Identifier) នេះ ហើយអត្តសញ្ញាណទាំងនោះត្រូវបានរក្សាទុកនៅលើឧបករណ៍ចល័ត/ទូរស័ព្ទដៃរបស់អ្នកផ្ទាល់។

5.3.3 5.3.3.ប្រសិនបើអ្នកអនុញ្ញាត ឬប្រើប្រាស់ឧបករណ៍កំណត់អត្តសញ្ញាណតាមជីវមាត្រ (Biometric Identifier) ដើម្បីចូលប្រើប្រាស់កម្មវិធី ABA Mobile អ្នកត្រូវធានាថា ឧបករណ៍កំណត់អត្តសញ្ញាណតាមជីវមាត្រ (Biometric Identifier) របស់អ្នកជាឧបករណ៍កំណត់អត្តសញ្ញាណតាមជីវមាត្រ (Biometric Identifier) តែមួយគត់រក្សាទុកនៅលើឧបករណ៍ចល័ត/ទូរស័ព្ទដៃដែលអ្នកប្រើប្រាស់ដើម្បីចូលប្រើប្រាស់កម្មវិធី ABA Mobile ។ ប៉ុន្តែប្រសិនបើ នរណាម្នាក់ផ្សេងទៀតបានរក្សាទុកឧបករណ៍កំណត់អត្តសញ្ញាណតាមជីវមាត្រ (Biometric Identifier) របស់ពួកគេនៅលើឧបករណ៍ចល័តដែលអ្នកបានប្រើប្រាស់ដើម្បីចូលប្រើប្រាស់កម្មវិធី ABA Mobile នោះវាជាការបំពានលក្ខខណ្ឌជាក់លាក់ ហើយអ្នកទទួលស្គាល់ថា ពួកគេនឹងអាចចូលប្រើប្រាស់គណនីរបស់អ្នក រួមទាំងពិនិត្យមើល និងធ្វើប្រតិបត្តិការមួយចំនួននៅលើកម្មវិធី ABA Mobile ហើយប្រតិបត្តិការទាំងនេះនឹងត្រូវចាត់ទុកថាត្រូវបានអ្នកអនុញ្ញាត និងធ្វើឡើងដោយអ្នកបានដឹង និងយល់ព្រម។

## 5.4 ការប្រើឧបករណ៍ចល័ត/ទូរស័ព្ទដៃដែលត្រូវបានកែសំណុំដើម (jailbroken or rooted)

ABA សូមណែនាំយ៉ាងទទូចថា អ្នកមិនត្រូវកែសំណុំដើមនៃប្រព័ន្ធដំណើរការទូរស័ព្ទដោយ jailbreak or root ឡើយ ព្រោះវានឹងធ្វើឲ្យប៉ះពាល់ដល់សមត្ថភាព ABA Mobile និងសុវត្ថិភាពព័ត៌មានសេវាធនាគាររបស់អ្នក រួមមានព័ត៌មានសម្ងាត់ និងពាក្យសម្ងាត់ជាដើម។ ប្រសិនបើអ្នកប្រើទូរស័ព្ទដែលត្រូវបានកែសំណុំដើមនៃប្រព័ន្ធដំណើរការ អ្នកនឹងត្រូវទទួលខុសត្រូវដោយខ្លួនឯងសម្រាប់រាល់ហានិភ័យដែលអាចកើតមាន។ ABA នឹងមិនទទួលខុសត្រូវ ហើយមិនរ៉ាប់រងលើរាល់ការខាតបង់ ឬការខូចខាត ដែលបង្កឡើងដោយការប្រើប្រាស់ទូរស័ព្ទកែសំណុំដើម (jailbreak ឬ root)។ សូមមើលចំណុច 8.1.1, 8.2.1, និង 8.3.3 ខាងក្រោម សម្រាប់សេចក្តីលម្អិត អំពីការទទួលខុសត្រូវរបស់អ្នក ពាក់ព័ន្ធការប្រើប្រាស់ទូរស័ព្ទកែសំណុំដើម (jailbreak ឬ root)។

# 6 ការទទួលស្គាល់របស់អ្នកប្រើប្រាស់

## 6.1 ការផ្ទេរប្រាក់

6.1.1 នៅពេលចាប់ផ្តើមការផ្ទេរប្រាក់ណាមួយ អ្នកត្រូវតម្រូវឲ្យផ្តល់ព័ត៌មានមួយចំនួនរបស់អ្នកទទួលដែលនឹងមានភាពផ្សេងពីគ្នាអាស្រ័យលើប្រភេទនៃការផ្ទេរប្រាក់។

6.1.2 នៅពេលធ្វើការផ្ទេរប្រាក់ទៅកាន់អ្នកទទួលដែលមានគណនី ABA ឬកាបូបឌីជីថលរបស់ក្រុមហ៊ុនផ្តល់សេវាទូទាត់ (PSP) នោះកម្មវិធី ABA Mobile នឹងបង្ហាញឈ្មោះរបស់អ្នកទទួលសម្រាប់គោលបំណងតែមួយគត់គឺជួយអ្នកក្នុងការកំណត់អត្តសញ្ញាណអ្នកទទួលការផ្ទេរប្រាក់តែប៉ុណ្ណោះ ហើយអ្នកយល់ព្រមមិនចែករំលែក ឬបង្ហាញឈ្មោះអ្នកទទួលទៅកាន់តតិយភាគីឡើយ។ ក្នុងករណីអ្នកចែករំលែក ឬបង្ហាញឈ្មោះអ្នកទទួលទៅកាន់តតិយភាគី នោះអ្នកយល់ព្រមថា អ្នកនឹងទទួលខុសត្រូវចំពោះការខូចខាត ឬការបាត់បង់ដែលយើងទទួលរង (រួមមានការបាត់បង់បន្តបន្ទាប់ និងការពិន័យដោយបទប្បញ្ញត្តិនានា) ដែលបណ្តាលមកពីការចែករំលែក ឬការបង្ហាញរបស់អ្នកនូវឈ្មោះ និងលេខគណនីរបស់អ្នកទទួលទៅកាន់តតិយភាគីណាមួយអនុលោមតាមប្រការ 9.3 ។

6.1.3 អ្នកផ្តល់ការយល់ព្រមច្បាស់លាស់ថា ធនាគារ ABA អាចបង្ហាញឈ្មោះរបស់អ្នកទៅកាន់នរណាម្នាក់ដែលប៉ុនប៉ងចាប់ផ្តើមការផ្ទេរប្រាក់មកអ្នកពីគណនី ABA របស់ពួកគេ ឬ កាបូបឌីជីថលរបស់ក្រុមហ៊ុនផ្តល់សេវាទូទាត់ (PSP) មកកាន់គណនី ABA របស់អ្នកនៅពេលដែលពួកគេដាក់បញ្ចូលលេខគណនីរបស់អ្នក ទោះនៅពេលការផ្ទេរប្រាក់មិនអាចបញ្ចប់ពេញលេញក៏ដោយ។

## 6.2 ការទូទាត់/ការទិញ

6.2.1 សម្រាប់ប្រតិបត្តិការទូទាត់/ទិញណាមួយដែលធ្វើឡើងតាមរយៈកម្មវិធី ABA Mobile អ្នកយល់ព្រមថា យើងអាចបង្ហាញឈ្មោះរបស់អ្នក និងព័ត៌មានលម្អិតអំពីការទូទាត់ដែលអ្នកបានធ្វើឡើងទៅឲ្យអ្នកលក់ ឬពាណិជ្ជករ ដើម្បីជូនដំណឹង ឬជួយពួកគេក្នុងការកំណត់អត្តសញ្ញាណប្រតិបត្តិការ។

6.2.2 យើងអាចលុនចោល ឬព្យួរការទូទាត់គ្រប់ពេលវេលាដោយមិនបាច់ជូនដំណឹងដល់អ្នកទទួល។ ក្នុងកាលៈទេសៈមួយចំនួន ធនាគារ ABA មិនអាចលុបចោលការទូទាត់ ឬទិញភ្លាមៗតាមការស្នើសុំរបស់អ្នកបង់ប្រាក់ឡើយ។ តាមការតម្រូវរបស់ច្បាប់ជាធរមាន ឬការរៀបចំផ្លូវច្បាប់នានា អ្នកនឹងត្រូវបានជូនដំណឹងតាមមធ្យោបាយផ្សេងៗ (រួមមានការជូនដំណឹង) អំពីការខកខាន ឬការលុបចោលការទូទាត់ក្នុងដំណាក់កាលសន្ទានកម្មផ្សេងៗជាច្រើន។ អ្នកមានកាតព្វកិច្ចក្នុងការពិនិត្យ និងទទួលស្គាល់ការលុបចោលទាំងនោះ។

## 6.3 ប្រតិបត្តិការតាមកាលវិភាគ និងប្រតិបត្តិការបន្តជាប្រចាំ

6.3.1 ABA Mobile ផ្តល់ជូនមុខងារ ផ្ទេរ/ទូទាត់តាមកាលវិភាគ ដែលអនុញ្ញាតឲ្យអ្នកប្រើប្រាស់កំណត់កាលវិភាគទូទាត់ជាមុនសម្រាប់កាតព្វកិច្ចហិរញ្ញវត្ថុផ្សេងៗ រួមមានជាអាទិ៍ ការទូទាត់វិក្កយបត្រ, ប្រាក់កម្ចី, ផ្ទេរប្រាក់ ទៅគណនី ABA ផ្សេង និងប្រតិបត្តិការបន្តជាប្រចាំ។ អ្នកប្រើប្រាស់អាចកំណត់កាលវិភាគថេរជាមួយនឹងចំនួនទឹកប្រាក់ថេរ ឬបញ្ជាក់ចំនួនទឹកប្រាក់ខុសៗគ្នា តាមប្រតិបត្តិការស្វ័យប្រវត្តិដែលព្រមព្រៀងអំឡុងពេលបង្កើតកាលវិភាគ។ តាមរយៈការប្រើប្រាស់មុខងារនេះ អ្នកទទួលស្គាល់ និងយល់ព្រមតាមខ និងលក្ខខណ្ឌខាងក្រោម៖

6.3.2 អ្នកទទួលខុសត្រូវទាំងស្រុងចំពោះការរៀបចំ និងការរក្សាទុក ការទូទាត់ប្រាក់តាមកាលវិភាគ នៅក្នុងកម្មវិធី ABA Mobile។ ទំនួលខុសត្រូវនេះ រួមមានជាអាទិ៍ ការធានានូវភាពត្រឹមត្រូវនៃព័ត៌មានទូទាត់ កាលបរិច្ឆេទទូទាត់ ហើយធានាថា អ្នកមានទឹកប្រាក់គ្រប់គ្រាន់ក្នុងគណនីដើម្បីទូទាត់ប្រាក់តាមកាលវិភាគ។

6.3.3 ធនាគារ ABA នឹងមិនទទួលខុសត្រូវចំពោះកំហុសឆ្គង ឬភាពមិនត្រូវគ្នាណាមួយ សម្រាប់ការទូទាត់តាមកាលវិភាគដែលអ្នកបានបង្កើតឡើយ។ អ្នកត្រូវតែផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃព័ត៌មានទូទាត់ ដូចជាព័ត៌មានលម្អិតរបស់អ្នកទទួល ចំនួនទឹកប្រាក់ទូទាត់ និងកាលបរិច្ឆេទទូទាត់ មុននឹងបញ្ជាក់ការទូទាត់តាមកាលវិភាគណាមួយ។

6.3.4 អ្នកទទួលខុសត្រូវក្នុងការធានាថា អ្នកមានទឹកប្រាក់គ្រប់គ្រាន់នៅក្នុងគណនីដើម្បីទូទាត់ប្រាក់តាមកាលវិភាគ នៅថ្ងៃ ដែលអ្នកបានកំណត់។ ធនាគារ ABA នឹងមិនទទួលខុសត្រូវចំពោះការចំណាយ/កម្ចីដកលើសសមតុល្យ (overdraft) ថ្លៃសេវា ឬការពិន័យនានាដែលបណ្តាលមកពីទឹកប្រាក់មិនគ្រប់គ្រាន់ ឬបញ្ហាដែលមិនបានព្រៀងទុកផ្សេងទៀត ក្នុងការទូទាត់ប្រាក់ដែលកំណត់តាមកាលវិភាគឡើយ។

6.3.5 អ្នកមានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យជាប្រចាំលើដំណើរការនៃការទូទាត់តាមកាលវិភាគរបស់អ្នកនៅក្នុងកម្មវិធី ABA Mobile។ ក្នុងករណីដែលការទូទាត់តាមកាលវិភាគមិនត្រូវបានដំណើរការតាមកាលកំណត់ក្រោមហេតុផលណាមួយ អ្នកត្រូវផ្ញើការទូទាត់ដោយចុចបញ្ចូលព័ត៌មានទូទាត់នោះឡើងវិញ ឬរាយការណ៍ទៅផ្នែកបម្រើសេវាអតិថិជនរបស់ធនាគារ ABA ឲ្យបានឆាប់បំផុត ដើម្បីចៀងវាងការពិន័យចំពោះការទូទាត់យឺតយ៉ាវ ឬការផាកពិន័យដែលធ្វើឡើងដោយភាគីទទួលប្រាក់។ ធនាគារ ABA នឹងមិនទទួលខុសត្រូវចំពោះការពិន័យលើការបង់យឺតយ៉ាវ ឬការផាកពិន័យណាមួយដែលធ្វើឡើងដោយភាគីទទួលប្រាក់ឡើយ។

6.3.6 អ្នកប្រើប្រាស់នឹងទទួលបានការជូនដំណឹង និងការបញ្ជាក់ទាក់ទងនឹង ការទូទាត់តាមកាលវិភាគ តាមរយៈកម្មវិធី ABA Mobile ឬមធ្យោបាយទំនាក់ទំនងដែលបានកំណត់ផ្សេងទៀត។ អ្នក ជាអ្នកទទួលខុសត្រូវក្នុងការពិនិត្យសារជូនដំណឹងទាំងនេះ ហើយរាយការណ៍ទៅធនាគារ ABA ភ្លាមៗអំពីភាពមិនច្បាស់លាស់ ឬភាពមិនប្រក្រតីណាមួយ។

### 6.4 ការដាក់ប្រាក់តាមម៉ាស៊ីនដាក់ប្រាក់

6.4.1 អ្នកយល់ព្រមថាឲ្យឈ្មោះរបស់អ្នក និងបញ្ជីគណនីរបស់អ្នកបង្ហាញនៅលើអេក្រង់ម៉ាស៊ីនដាក់ប្រាក់បន្ទាប់ពីកូដ QR ត្រូវបានស្កេនតាមរយៈកម្មវិធី ABA Mobile ដែលបានដំឡើងនៅលើឧបករណ៍របស់អ្នក។

### 6.5 ABA Pay

6.5.1 អ្នកយល់ព្រមឲ្យគណនីរបស់អ្នករាយបញ្ជី និងបង្ហាញនៅពេលអ្នកស្កេនកូដ QR ជាមួយកម្មវិធី ABA Mobile ដែលបានដំឡើងលើឧបករណ៍របស់អ្នក។ ដោយមានការផ្ទៀងផ្ទាត់សុពលភាពមួយចំនួន គណនីមានលក្ខណៈមិនពេញមួយចំនួនមិនត្រូវបានបង្ហាញសម្រាប់ការជ្រើសរើសឡើយ។

### 6.6 អត្រាប្តូរប្រាក់

6.6.1 អ្នកយល់ព្រមថា អត្រាប្តូរប្រាក់ និងការគណនាដែលបង្ហាញនៅក្នុងកម្មវិធី ABA Mobile គឺសម្រាប់ជាឯកសារយោងទូទៅតែប៉ុណ្ណោះ ហើយអ្នកយល់ថា អត្រាប្តូរប្រាក់នៅក្នុងកម្មវិធី ABA Mobile មិនអាចបង្ហាញក្នុងពេលវេលាជាក់ស្តែង ហើយអត្រាប្តូរប្រាក់អនុវត្តចំពោះអ្នកក្នុងប្រតិបត្តិជាក់ស្តែងរបស់អ្នកអាចខុសពីអត្រាប្តូរប្រាក់ដែលបង្ហាញនៅក្នុងកម្មវិធី ABA Mobile ។

### 6.7 ការជូនដំណឹង

6.7.1 ការជូនដំណឹងតាមសារ SMS

ក. អ្នកយល់ព្រមថា តាមរយៈការចុះឈ្មោះសម្រាប់កម្មវិធី ABA Mobile ធនាគារ ABA អាចផ្ញើ ឬត្រូវបានស្នើឲ្យផ្ញើសារ SMS ទៅកាន់ឧបករណ៍ចល័តរបស់អ្នក។

ខ. ធនាគារ ABA មិនទទួលខុសត្រូវចំពោះការខាត់បង់ ឬការខូចខាតដែលអ្នកទទួលរងបណ្តាលមកពីនរណាម្នាក់ដែលមិនមែនអ្នកដោយចូលប្រើប្រាស់សារ SMS និងមាតិការបស់សារទាំងនោះបណ្តាលមកពីការធ្វេសប្រហែសរបស់អ្នក។

គ. អ្នកអាចទទួលរងបន្ទុកពីប្រតិបត្តិករទូរស័ព្ទបណ្តាលមកពីការប្រើប្រាស់កម្មវិធី ABA Mobile ឬសារ SMS។ បន្ទុកណាមួយគឺជាការទទួលខុសត្រូវរបស់អ្នកតែប៉ុណ្ណោះ។

6.7.2 ការជូនដំណឹងតាមកម្មវិធី

ក. អ្នកយល់ព្រមទទួលការផ្តល់សញ្ញា ឬការជូនដំណឹងសម្រាប់គណនី ABA របស់អ្នកសម្រាប់ប្រតិបត្តិការមួយចំនួន ឬការទំនាក់ទំនងផ្សព្វផ្សាយផ្នែកទីផ្សារ ឬការប្រកាសព័ត៌មានពីធនាគារ ABA។

## 7 កាតព្វកិច្ចរបស់អ្នក

**7.1** អ្នកមិនត្រូវប្រើប្រាស់កម្មវិធី ABA Mobile សម្រាប់គោលបំណងណាមួយមិនមែនដើម្បីធ្វើការសាកសួរ ឬប្រតិបត្តិការសេវាធនាគារស្របច្បាប់នៅលើគណនីនានាដែលអ្នកមានសិទ្ធិស្របច្បាប់ក្នុងការប្រតិបត្តិការអនុលោមតាមលក្ខខណ្ឌជាក់លាក់ និងលក្ខខណ្ឌអនុវត្តចំពោះអ្នក។

**7.2** អ្នកមិនត្រូវប្រើកម្មវិធី ABA Mobile សម្រាប់សកម្មភាពអាជីវកម្មហាមឃាត់នានាឡើយ។

**7.3** អ្នកមិនត្រូវធ្វើសកម្មភាពក្លែងបន្លំ ឬគ្រោះថ្នាក់ពាក់ព័ន្ធនឹងកម្មវិធី ABA Mobile ឬកម្មវិធីរបស់វាឡើយ។ ឧទាហរណ៍ អ្នកមិនត្រូវចម្លង កែប្រែ ធ្វើឲ្យប៉ះពាល់អវិជ្ជមាន បំប្លែងវិស្វកម្ម ហែគចូលប្រើប្រាស់ ឬបញ្ចូលកូដគ្រោះថ្នាក់ចូលក្នុងកម្មវិធី ABA Mobile ឬកម្មវិធីរបស់វា។

**7.4** ប្រសិនបើអ្នកប្រើប្រាស់រូបថតនានាដើម្បីកែគណនីរបស់អ្នកតាមចិត្តអ្នកដែលអាចត្រូវបានចូលប្រើប្រាស់បានតាមរយៈកម្មវិធី ABA Mobile អ្នកធានាថា៖

ក. រូបថតដែលអ្នកប្រើមិនមានមាតិកាដែលបំពាន ឬខុសច្បាប់ ឬនឹងត្រូវចាត់ទុកថាមិនអាចទទួលយកបានសម្រាប់ការពិនិត្យមើលដោយបុគ្គលដែលមានអាយុតិចជាង 18 ឆ្នាំ និង

ខ. អ្នកបានថតរូប (ឬជាម្ចាស់សិទ្ធិថតចម្លងនៃរូបថតនោះ)។

**7.5** អ្នកទទួលស្គាល់ថា អ្នកទទួលខុសត្រូវចំពោះ និងត្រូវប្រុងប្រយ័ត្នសមស្របទាំងអស់ក្នុងការធានាថា ព័ត៌មានដែលអាចផ្តល់តាមរយៈកម្មវិធី ABA Mobile ពិត ពេញលេញ ត្រឹមត្រូវ និងទាន់បច្ចុប្បន្នភាព។

## 8 ការទទួលខុសត្រូវ និងការសងសំណង

### 8.1 ការទទួលខុសត្រូវរបស់ធនាគារ ABA

8.1.1 ធនាគារ ABA មិនទទួលខុសត្រូវចំពោះការខាតបង់ណាមួយបណ្តាលមកពីការប្រើប្រាស់កម្មវិធី ABA Mobile របស់អ្នកឡើយ រួមមានការខាតបង់បណ្តាលមកពីការបំពានសុវត្ថិភាពណាមួយ ប្រសិនបើអ្នកបានធ្វើសកម្មភាពក្លែងបន្លំ (តែម្នាក់ឯង ឬរួមគ្នាជាមួយនរណាម្នាក់

ផ្សេងទៀត) ប្រសិនបើអ្នកបានដំឡើងកម្មវិធីនៅលើឧបករណ៍ចល័ត/ទូរស័ព្ទដៃរបស់អ្នកដែលមិនមែនជាកម្មវិធីដែលមាននៅលើ Apple App Store ឬ Google Play Store ឬប្រសិនបើអ្នកបង្ក ឬរួមចំណែកដល់ការខាតបង់នោះ ឧទាហរណ៍ ដោយមិនប្រតិបត្តិតាមលក្ខខណ្ឌជាក់លាក់ណាមួយ ឬលក្ខខណ្ឌអនុវត្តផ្សេងៗ។ វាជាជម្រើសរបស់អ្នកក្នុងការដោនឡូត និងដំឡើងកម្មវិធី ABA Mobile។ ក្នុងកម្រិតអនុញ្ញាតដោយច្បាប់ ធនាគារ ABA មិនទទួលខុសត្រូវចំពោះការខាតបង់ ឬផលវិបាកណាមួយចំពោះអ្នកឡើយទោះលទ្ធផលណាមួយក៏ដោយដែលបណ្តាលមកពីការសម្រេចចិត្តនេះ រួមមាន ក្នុងករណីធនាគារ ABA បដិសេធ ឬមិនបានដំណើរការសំណើរសុំធ្វើប្រតិបត្តិការ ឬពន្យារពេលដំណើរការធ្វើប្រតិបត្តិការ។

## 8.2 កម្រិតការទទួលខុសត្រូវរបស់ធនាគារ ABA

8.2.1 ក្នុងកម្រិតអនុញ្ញាតដោយច្បាប់ យើងមិនទទួលខុសត្រូវចំពោះអ្នកចំពោះការចំណាយ ការខាតបង់ ការខូចខាត ឬបំណុលផ្ទាល់ ឬប្រយោលនានា បណ្តាលមកពី៖

ក. អ្នកប្រើប្រាស់សេវាកម្មណាមួយដែលផ្តល់ជូនតាមរយៈកម្មវិធី ABA Mobile

ខ. អ្នកប្រើឧបករណ៍ចល័ត/ទូរស័ព្ទដៃដែលត្រូវបានកែសំណុំដើម (jailbroken or rooted)

គ. អ្នកមិនបានប្រតិបត្តិតាមលក្ខខណ្ឌជាក់លាក់

ឃ. ការពន្យារពេល ឬការបាត់បង់ការចូលប្រើប្រាស់ ឬការប្រើប្រាស់ប្រតិបត្តិករទូរស័ព្ទណាមួយគ្រប់ពេលវេលា

ង. បញ្ហា ឬកំហុសណាមួយក្នុងការរចនា មាតិកា ឬវិស្វកកម្មរបស់ប្រតិបត្តិករទូរស័ព្ទណាមួយដែលហួសពីការគ្រប់គ្រងរបស់យើង

ច. ការខូចឧបករណ៍ ឬប្រព័ន្ធណាមួយ ឬការដាច់លីងទូរគមនាគមន៍ណាមួយ ឬ

ឆ. មូលហេតុ ឬព្រឹត្តិការណ៍ណាមួយហួសពីការគ្រប់គ្រងរបស់យើង

8.2.2 ធនាគារ ABA មិនមានសិទ្ធិអំណាចក្នុងការធ្វើសកម្មភាព ឬទទួលកាតព្វកិច្ចណាមួយជំនួសប្រតិបត្តិករទូរស័ព្ទណាមួយឡើយ

8.2.3 ធនាគារ ABA គ្រប់ពេលវេលា មិនធ្វើជាភ្នាក់ងារ ឬដៃគូប្រតិបត្តិករទូរស័ព្ទណាមួយក្នុងការផ្តល់សេវាទូរស័ព្ទណាមួយ ហើយធនាគារ ABA មិនតំណាង ឬផ្តល់ការតំណាងណាមួយដែលថាមានទំនាក់ទំនងបែបនោះឡើយ។

## 8.3 ការទទួលខុសត្រូវរបស់អ្នក

8.3.1 អ្នកទទួលស្គាល់ថា ការណ៍ដែលអ្នកបង្កើតឡើងវិញនូវព័ត៌មានដែលជាកម្មសិទ្ធិដែលផ្តល់ជូន ឬមានតាមរយៈកម្មវិធី ABA Mobile ឬផ្នែកណាមួយនៃកម្មវិធីនេះអាចបណ្តាលឲ្យមានការចាត់វិធានការផ្លូវច្បាប់។

8.3.2 អ្នកនឹងទទួលខុសត្រូវចំពោះការខាតបង់ណាមួយដែលយើងទទួលរង (រួមមានការខាតបង់ដែលជាផលវិបាក) ដែលបណ្តាលមកពីការក្លែងបន្លំ ឬការធ្វេសប្រហែសរបស់អ្នក ឬការបំពានរបស់អ្នកនូវលក្ខខណ្ឌជាក់លាក់។ អ្នកនឹងទទួលខុសត្រូវចំពោះការខាតបង់ចំពោះខាតបង់ណាមួយដែលយើងទទួលរងបណ្តាលមកពីការចូលប្រើប្រាស់គ្មានការអនុញ្ញាត ឬការប្រើប្រាស់នូវសេវាកម្មណាមួយដែលមានក្នុងកម្មវិធី ABA Mobile និងដែលអ្នកបានរួមចំណែកតាមរយៈការមិនប្រតិបត្តិតាមលក្ខខណ្ឌជាក់លាក់។ ការណ៍នេះរួមមាន ប្រសិនបើអ្នក៖

ក. ជ្រើសរើសសម្ងាត់ (PIN) មិនសមស្រប

ខ. មិនបានការពារសមស្របនូវលេខសម្ងាត់ (PIN) របស់អ្នក

គ. មិនបានបិទការផ្ទៀងផ្ទាត់ជីវមាត្រនៅលើកម្មវិធី ABA Mobile នៅពេលអ្នកដឹង ឬសង្ស័យថា អ្នកផ្សេងអាចបើកសោឧបករណ៍ចល័តរបស់អ្នកបាន ឬបានរក្សាទុកឧបករណ៍កំណត់អត្តសញ្ញាណតាមជីវមាត្រ (Biometric Identifier) របស់ពួកគេនៅលើឧបករណ៍ចល័តរបស់អ្នក

ឃ. មិនបានផ្ទៀងផ្ទាត់ព័ត៌មានអ្នកទទួលមុនពេលធ្វើការផ្ទេរប្រាក់ ឬទូទាត់ដែលនាំឲ្យមានការខាតបង់ផ្ទាល់ ឬប្រយោល ឬ

ង. អ្នកពន្យារពេលមិនសមស្របក្នុងការជូនដំណឹងមកយើងអំពី៖ (i) ការបាត់បង់ ឬចោរលួចទូរស័ព្ទដៃ ឬឧបករណ៍ចល័ត ឬអត្តសញ្ញាណសុវត្ថិភាពរបស់អ្នក (ii) ការបង្ហាញជាក់ស្តែង ឬសង្ស័យដល់អ្នកផ្សេងនូវលេខកូដ PIN (iii) នៅពេលអ្នកដឹង ឬសង្ស័យថា អ្នកផ្សេងអាចដោះសោឧបករណ៍ចល័តរបស់អ្នក និង/ឬរក្សាទុកឧបករណ៍កំណត់អត្តសញ្ញាណតាមជីវមាត្រ (Biometric Identifier) នៅលើឧបករណ៍ចល័ត/ទូរស័ព្ទដៃរបស់អ្នក ហើយអ្នកបានបើកការផ្ទៀងផ្ទាត់ជីវមាត្រនៅលើកម្មវិធី ABA Mobile ឬ (iv) ដែលថា មាន ឬអ្នកសង្ស័យថាមានការចូលប្រើប្រាស់ ឬសកម្មភាពដែលគ្មានការអនុញ្ញាតតាមរយៈកម្មវិធី ABA Mobile ។

8.3.3 អ្នកនឹងទទួលខុសត្រូវចំពោះការខាតបង់ណាមួយដែលដែលកើតមានចំពោះអ្នក និងធនាគារ ប្រសិនបើអ្នកប្រើឧបករណ៍ចល័ត/ទូរស័ព្ទដៃដែលត្រូវបានកែសំណុំដើម (jailbroken or rooted)។

**8.4 កម្រិតការទទួលខុសត្រូវរបស់អ្នក**

8.4.1 អ្នកមិនទទួលខុសត្រូវចំពោះការខាតបង់ណាមួយបណ្តាលមកពី៖

ក. យើងធ្វើសកម្មភាពក្លែងបន្លំ ឬធ្វេសប្រហែស ឬ

ខ. បញ្ហាកើតឡើងក្នុងម៉ាស៊ីន ឬប្រព័ន្ធដែលប្រើប្រាស់ជាផ្នែកនៃប្រព័ន្ធ ABA Mobile លុះត្រាតែបញ្ហានោះច្បាស់ ឬអ្នកត្រូវបានប្រាប់ឲ្យដឹងពីបញ្ហានោះតាមរយៈសារ ឬការជូនដំណឹងលើអេក្រង់ និងការខាតបង់ដែលកើតឡើងបន្ទាប់ពីការជូនដំណឹងនេះ។

# 9 វិវាទជាមួយពាណិជ្ជករ ឬអ្នកលក់

9.1 ធនាគារ ABA មិនទទួលខុសត្រូវចំពោះការទិញ ឬការទូទាត់ណាមួយ ឬការទូទាត់ដែលបានធ្វើឡើងតាមសេវាកម្មស្កេន QR ឬជម្រើសការទូទាត់ផ្សេងៗដែលបង្ហាញក្នុងកម្មវិធី ABA Mobile ប្រសិនបើ៖

ក. មានឱនភាព ឬកង្វះខាតក្នុងការផ្តល់ទំនិញ ឬសេវាកម្មនានា

ខ. អ្នកសម្រេចចិត្តថា អ្នកលែងត្រូវការទំនិញ ឬសេវាកម្មនានានោះ

9.2 វិវាទណាមួយត្រូវដោះស្រាយរវាងអ្នក និងពាណិជ្ជករ ឬអ្នកលក់ដោយផ្ទាល់។

9.3 ការទូទាត់តាមរយៈកម្មវិធី ABA Mobile អ្នកត្រូវតែទទួលស្គាល់ និងយល់ព្រមថាធនាគារ ABA មិនទទួលខុសត្រូវចំពោះគុណភាព សុវត្ថិភាព ភាពស្របច្បាប់ ឬទិដ្ឋភាពផ្សេងទៀតនៃផលិតផល ឬសេវាកម្មដែលផ្តល់ដោយពាណិជ្ជករ ឬអ្នកលក់ទាំងនេះទេ។ ធនាគារ ABA មិនទទួលខុសត្រូវចំពោះការបាត់បង់ ការខូចខាត ឬវិវាទដែលកើតចេញពីការប្រើប្រាស់សេវាកម្មភាគីទីបីទាំងនេះទេ ហើយអ្នកត្រូវតែទទួលខុសត្រូវក្នុងការដោះស្រាយបញ្ហាណាមួយដោយផ្ទាល់ជាមួយពាណិជ្ជករ ឬអ្នកលក់។

9.4 អ្នកទទួលខុសត្រូវចំពោះការប្រើប្រាស់ការប្រុងប្រយ័ត្នសមស្រប និងដឹងពីហានិភ័យក្នុងការទូទាត់សម្រាប់ទំនិញ និងសេវាកម្មមុនទទួលបានទំនិញ និងសេវាកម្មទាំងនោះ។ អ្នកគួរពិចារណាពីកេរ្តិ៍ឈ្មោះរបស់បុគ្គល ឬនីតិបុគ្គលដែលអ្នកកំពុងធ្វើអាជីវកម្មជាមួយ រួមមាន នៅពេលទិញទំនិញ ឬសេវាកម្មដែលមិនជួបមុខគ្នាផ្ទាល់។

9.5 ប្រសិនបើអ្នកមានវិវាទជាមួយពាណិជ្ជករ ឬអ្នកលក់ អ្នកនៅតែត្រូវទូទាត់ចំនួនទឹកប្រាក់ទាំងអស់ដែលជំពាក់យើងដែរ។

# 10 ការព្យួរ ឬការបញ្ឈប់កម្មវិធី ABA MOBILE

10.1 អ្នកអាចលុបចោលការប្រើប្រាស់កម្មវិធី ABA Mobile គ្រប់ពេលវេលាដោយជូនដំណឹងធនាគារ ABA ជាលាយលក្ខណ៍អក្សរ ឬតាមទូរស័ព្ទ។ អ្នកនៅតែទទួលខុសត្រូវចំពោះប្រតិបត្តិការដែលបានធ្វើឡើងនៅលើគណនីរបស់អ្នក/ប្រើប្រាស់កម្មវិធី ABA Mobile រហូតមកដល់ពេលដែលការលុបចោលការប្រើប្រាស់នោះមានប្រសិទ្ធភាព។

10.2 ធនាគារ ABA អាចដកការចូលប្រើប្រាស់គ្រប់ពេលវេលាដោយមិនបាច់ជូនដំណឹងជាមុន ព្យួរ និង/ឬបញ្ឈប់ ការចូលប្រើប្រាស់កម្មវិធី ABA Mobile ឬសេវាកម្មណាមួយរបស់កម្មវិធីនេះដោយមូលហេតុណាមួយ រួមមាន (ប៉ុន្តែមិនកម្រិតចំពោះ) នៅពេលដែលធនាគារ ABA យល់ឃើញថា អ្នកបានធ្វើសកម្មភាពដែលបំពានលក្ខខណ្ឌជាក់លាក់នោះ។

10.3 ក្នុងករណីអ្នកផ្លាស់ប្តូរឧបករណ៍ចល័ត ហើយមានបំណងបន្តប្រើប្រាស់កម្មវិធី ABA Mobile អ្នកត្រូវដោនឡូតកម្មវិធី ABA Mobile ដាក់លើឧបករណ៍ចល័តថ្មីរបស់អ្នក ហើយអនុវត្តតាមដំណើរការចុះឈ្មោះ។ អ្នកអាចលុបចោលកម្មវិធី ABA Mobile ពីឧបករណ៍ដែលមានស្រាប់របស់អ្នកមុនពេល ឬអំឡុងពេលដំណើរការចុះឈ្មោះសម្រាប់ឧបករណ៍ថ្មីរបស់អ្នក។

# 11 លក្ខខណ្ឌឯកជនភាព

11.1 អនុលោមតាមលក្ខខណ្ឌតម្រូវបទប្បញ្ញត្តិរបស់កម្ពុជា និងគោលនយោបាយផ្ទៃក្នុងរបស់ធនាគារ ABA អ្នកផ្តល់ការយល់ព្រមច្បាស់លាស់ និងយល់ព្រមថា៖

ក. ជាផ្នែកនៃការបំពេញតាមលក្ខខណ្ឌតម្រូវនៃគោលការណ៍ស្គាល់អតិថិជនរបស់ខ្លួន (KYC) របស់ធនាគារ ABA កម្មវិធី ABA Mobile អាចប្រមូលព័ត៌មានផ្ទាល់ខ្លួនពីអ្នក នោះអ្នកជានា និងផ្តល់ការធានាថា ព័ត៌មានផ្ទាល់ខ្លួនដែលអ្នកផ្តល់តាមរយៈកម្មវិធី ABA Mobile ពិតពេញលេញ និងទាន់បច្ចុប្បន្នភាព។ លើសពីនេះ អ្នកទទួលស្គាល់ និងយល់ព្រមថា ការមិនផ្តល់ព័ត៌មានផ្ទាល់ខ្លួនទាន់ បច្ចុប្បន្នភាពតាមការតម្រូវរបស់កម្មវិធី ABA Mobile នឹងបណ្តាលឲ្យមានភាពមិនងាយស្រួល និងការកម្រិតការចូលប្រើប្រាស់មុខងាររបស់កម្មវិធី ABA Mobile ។

ខ. ព័ត៌មានផ្ទាល់ខ្លួនដែលប្រមូលបានជាផ្នែកនៃអត្តសញ្ញាណរបស់អ្នកអាចត្រូវធនាគារ ABA រក្សាទុកសម្រាប់គោលបំណងអនុញ្ញាតឲ្យអ្នកប្រើប្រាស់សេវាកម្មនានាដែលផ្តល់ដោយធនាគារ ABA ។

គ. ធនាគារ ABA អាចប្រមូលព័ត៌មានណាមួយអំពីអាកប្បកិរិយាប្រើប្រាស់សម្រាប់គោលបំណងពង្រឹងសុវត្ថិភាព និងការកែលម្អបទពិសោធអ្នកប្រើប្រាស់។

ឃ. ធនាគារ ABA អាចតម្រូវឲ្យអ្នកបើកការបង្ហាញទីតាំងនៅលើឧបករណ៍ចល័តរបស់អ្នក ហើយប្រើប្រាស់ទិន្នន័យនេះ។ ទិន្នន័យនេះនឹងយកមកប្រើដើម្បីពង្រឹងសុវត្ថិភាពលើការប្រើប្រាស់កម្មវិធី ABA Mobile ធ្វើអោយប្រសើរឡើងនូវមុខងារជាក់លាក់មួយចំនួន និងដើម្បីផ្តល់ជូនជាប្រយោជន៍ផ្សេងៗដែលទាក់ទិននឹងមុខងារបង្ហាញទីតាំង។

ង. ABA អាចពិនិត្យមើលអត្តសញ្ញាណទូរស័ព្ទដៃ (Mobile Identity) របស់អ្នកនៅពេលអ្នកចុះឈ្មោះឬបើកដំណើរការ ABA Mobile ធ្វើបច្ចុប្បន្នភាពព័ត៌មានផ្ទាល់ខ្លួន ឬធ្វើប្រតិបត្តិការដែលជាផ្នែកមួយនៃវិធានការសុវត្ថិភាពក្នុងការប្រើប្រាស់កម្មវិធីទូរស័ព្ទ ABA ។

**11.2** ធនាគារ ABA ក៏អាចតម្រូវដោយបទប្បញ្ញត្តិមួយចំនួនឲ្យបង្ហាញព័ត៌មានផ្ទាល់ខ្លួន និងព័ត៌មានសម្ងាត់របស់អ្នកពាក់ព័ន្ធនឹងប្រតិបត្តិការគណនីរបស់អ្នក ហើយអ្នកព្រម និងយល់ព្រមច្បាស់លាស់ចំពោះការបង្ហាញព័ត៌មានទាំងនេះ។

**11.3** ABA Mobile ប្រើប្រាស់ Facebook Software Development Kit (SDK) ក្នុងគោលបំណង បង្កើនប្រសិទ្ធភាពការងារផ្សព្វផ្សាយទីផ្សាររបស់ខ្លួន។ យើងខ្ញុំសូមគូសបញ្ជាក់ថា ធនាគារ ABA មិនចូលប្រើប្រាស់ ឬ ប្រមូលព័ត៌មានសម្គាល់អត្តសញ្ញាណបុគ្គល ឬ ទិន្នន័យជាក់លាក់ណាមួយរបស់អ្នកប្រើប្រាស់ តាមរយៈ Facebook SDK ឡើយ។ ព័ត៌មានដែលប្រមូលតាមរយៈផ្លែតហ្វមនេះ អាចរួមមាន ព័ត៌មានប្រជាសាស្ត្រទូទៅ ដូចជា អាយុ ភេទ និងស្ថិតិនៃការប្រើប្រាស់ជារួម។ យើងខ្ញុំសូមធានាថា ធនាគារ ABA នឹងផ្តល់អាទិភាពខ្ពស់បំផុតក្នុងការគោរពឯកជនភាព និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់របស់ខ្លួន។ រាល់ទិន្នន័យដែលប្រមូលបានតាមរយៈ Facebook SDK នឹងត្រូវប្រើប្រាស់ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីការការពារទិន្នន័យ ជាធរមាន។ ធនាគារ ABA នឹងមិនធ្វើការចែករំលែក ឬផ្តល់ទិន្នន័យទាំងនោះ ទៅដល់ភាគីទីបីណាមួយ សម្រាប់គោលបំណងទីផ្សារ ឬសកម្មភាពប្រូម៉ូសិនផ្សេងៗឡើយ។

**11.4** តាមរយៈការប្រើប្រាស់ ABA Mobile អ្នកផ្តល់ការយល់ព្រមយ៉ាងច្បាស់លាស់ និងព្រមព្រៀងថា ABA អាចចែករំលែកព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកជាមួយភាគីទីបី ដោយអនុលោមតាមកាតព្វកិច្ចច្បាប់។ នេះអាចរាប់បញ្ចូលស្ថានភាពដែល ABA ជឿជាក់ និងដោយស្មារតីនៃភាពស្មោះត្រង់ ថា វាត្រូវបានតម្រូវដោយច្បាប់ជាធរមាន ឬតាមសំណើរបស់អាជ្ញាធររដ្ឋាភិបាល។ ការចែករំលែកព័ត៌មាន ក៏អាចចាំបាច់ផងដែរក្នុងការផ្ទៀងផ្ទាត់ ឬអនុវត្តសិទ្ធិតាមកិច្ចសន្យារបស់យើង, រក្សាគោលនយោបាយពាក់ព័ន្ធ, តាមដាន និងការពារប្រឆាំងនឹងការក្លែងបន្លំ, ដោះស្រាយភាពងាយរងគ្រោះនៃផ្នែកបច្ចេកទេស ឬសុវត្ថិភាព, ឆ្លើយតបទៅនឹងភាពអាសន្ន ឬបើកឲ្យអ្នកផ្តល់សេវាតតិយភាគី ផ្តល់សេវាកម្មសំខាន់ៗសម្រាប់ ABA ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនក្រោម ខ និងលក្ខខណ្ឌជាក់លាក់។ ក្នុងករណីមានការចូលប្រើប្រាស់ដោយគ្មានការអនុញ្ញាត ឬការបំពានលើព័ត៌មានរបស់អ្នកដោយភាគីទីបី អ្នកយល់ព្រមថា នឹងមិនទាមទារឲ្យ ABA ទទួលខុសត្រូវណាមួយឡើយ ដោយស្វែងរកវិធានការផ្លូវច្បាប់ប្រឆាំងនឹងភាគីល្មើសផ្ទាល់។

**11.5** ដោយប្រតិបត្តិតាមលក្ខខណ្ឌតម្រូវនៃគោលការណ៍ស្គាល់អតិថិជន (KYC) និងដើម្បីធានាបាននូវភាពត្រឹមត្រូវ និងពិតប្រាកដនៃអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (NID) របស់អ្នក អ្នកផ្តល់នូវការយល់ព្រមយ៉ាងច្បាស់លាស់ឲ្យធនាគារ ABA ចែករំលែកឈ្មោះ នាមត្រកូល ថ្ងៃខែឆ្នាំកំណើត លេខអត្តសញ្ញាណប័ណ្ណ និងកាលបរិច្ឆេទផុតកំណត់នៃព័ត៌មានទាំងនេះជាមួយ CamDX។ ការចែករំលែកព័ត៌មាននេះធ្វើឡើងក្នុងគោលបំណងផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់អ្នកតែមួយមុខគត់។ ធនាគារ ABA រក្សាការសម្ងាត់ និងវិធានការសុវត្ថិភាពយ៉ាងតឹងរ៉ឹង ដើម្បីការពារទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកអំឡុងពេលដំណើរការផ្ទៀងផ្ទាត់នេះ។ តាមរយៈការផ្តល់ការយល់ព្រមនេះ អ្នកទទួលស្គាល់ និងយល់ព្រមចំពោះការចែករំលែកព័ត៌មានដែលបានបញ្ជាក់ជាមួយ CamDX សម្រាប់គោលបំណងដែលបានចែង។

## 12 លក្ខខណ្ឌជាក់លាក់បន្ថែម

**12.1** មុខងារផ្សេងៗ ដូចជា ដាក់បញ្ញើ បង្កើតកាតនិម្មិត ABA PAY កម្ចីភ្លាមៗ និងសេវាកម្មផ្សេងៗដែលអ្នកចូលប្រើប្រាស់ដោយប្រើកម្មវិធី ABA Mobile និងប្រតិបត្តិការនីមួយៗដែលបានធ្វើឡើងនៅក្នុងគណនីនៅតែអនុវត្តតាមលក្ខខណ្ឌជាក់លាក់ដែលគ្រប់គ្រងមុខងារទាំងនោះនីមួយៗ។

## 13 កម្មសិទ្ធិបញ្ញា

**13.1** ធនាគារ ABA មាន ឬបានទទួលអាជ្ញាប័ណ្ណមានសុពលភាពក្នុងការប្រើប្រាស់កម្មសិទ្ធិបញ្ញាទាំងអស់ដែលប្រើប្រាស់ពាក់ព័ន្ធនឹងការផ្តល់កម្មវិធី ABA Mobile ។ ព័ត៌មានដែលបានផ្តល់ដល់អ្នកជាផ្នែកនៃកម្មវិធី ABA Mobile អាចត្រូវបានប្រើប្រាស់សម្រាប់តែការប្រើប្រាស់ផ្ទាល់ខ្លួន និងជាឯកសារយោងប៉ុណ្ណោះ ហើយមិនអាចបង្កើតឡើងវិញ ចែកចាយ ឬបញ្ជូនទៅកាន់នរណាម្នាក់ ឬបានដាក់បញ្ចូលក្នុងឯកសារផ្សេងៗណាមួយដោយគ្មានការយល់ព្រមជាលាយលក្ខណ៍ជាមុនពីធនាគារ ABA ។

## 14 វិសោធនកម្ម

**14.1** ធនាគារ ABA អាចផ្លាស់ប្តូរលក្ខខណ្ឌជាក់លាក់គ្រប់ពេលវេលា។ ប្រសិនបើដូច្នេះ ធនាគារ ABA នឹងតែងតែជូនដំណឹងសមស្របដែលតម្រូវដោយច្បាប់ជាធរមាន និងទំនាក់ទំនងការផ្លាស់ប្តូរទាំងនេះ តាមរយៈការទំនាក់ទំនងផ្ទាល់តាមអេក្រង់នៅតាមសាខា ABA តាមរយៈការជូនដំណឹងតាមប្រព័ន្ធផ្សព្វផ្សាយ (រួមមានការជូនដំណឹងសាធារណៈ) តាមការជូនដំណឹងលើវែបសាយរបស់ធនាគារ ABA ឬវិធីសាស្ត្រទំនាក់ទំនងអេឡិកត្រូនិកផ្សេងៗដែលអ្នកប្រើប្រាស់។

## 15 ដំណោះស្រាយវិវាទ និងច្បាប់គ្រប់គ្រង

**15.1** វិវាទណាមួយកើតឡើងពី ឬពាក់ព័ន្ធនឹងលក្ខខណ្ឌជាក់លាក់ រួមមានបញ្ហាណាមួយពាក់ព័ន្ធនឹងអត្ថិភាពនៃបញ្ហានោះ សុពលភាព ការអនុវត្ត ឬការបញ្ចប់ ត្រូវបញ្ជូនទៅកាន់ និងជាចុងក្រោយដោះស្រាយដោយមជ្ឈត្តការនៅក្នុងព្រះរាជាណាចក្រកម្ពុជា អនុលោមតាមវិធានមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការពាណិជ្ជកម្ម ("វិធាន NCAC") ជាធរមាននៅពេលចាប់ផ្ដើមមជ្ឈត្តការ និងតាមយោងនៅក្នុងប្រការនេះ នោះវិធានមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការពាណិជ្ជកម្ម ត្រូវបានចាត់ទុកថាបានដាក់បញ្ចូលជាផ្នែកនៃកិច្ចសន្យានេះ។ តុលាការនឹងមានមជ្ឈត្តករមួយរូប។ ភាសានៃមជ្ឈត្តការត្រូវតែជាភាសាអង់គ្លេស។ លក្ខខណ្ឌជាក់លាក់ត្រូវបានគ្រប់គ្រងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

# ឧបសម្ព័ន្ធ ក

បញ្ជីសេវាកម្ម និងមុខងារសំខាន់ៗមាននៅលើកម្មវិធី ABA Mobile គិតត្រឹមខែតុលា 2023

### គណនី

នៅផ្នែកគណនី អ្នកប្រើប្រាស់អាចឃើញគណនីទាំងអស់ដែលមានជាមួយធនាគារ ABA និងអាចចូលប្រើប្រាស់មុខងារ និងសេវាកម្ម ដូចខាងក្រោម៖

- ពិនិត្យមើលគណនីទាំងអស់
- បើកភ្លាមៗនូវគណនីសន្សំថ្មី គណនីបត់បែនប្រាក់រៀលតាមទូរស័ព្ទ គណនីបញ្ញើមានកាលកំណត់តាមទូរស័ព្ទជាប្រាក់ដុល្លារ ឬប្រាក់រៀល
- ពិនិត្យមើលសមតុល្យគណនី
- លាក់/បង្ហាញគណនីមួយ ឬច្រើនពីបញ្ជីគណនី
- ប្ដូរឈ្មោះគណនីទៅជាឈ្មោះជាទីពេញចេញ
- បើកដំណើរការ/បិទសារជូនដំណឹងសម្រាប់ប្រតិបត្តិការស្ថិតក្រោមគណនីជាក់លាក់
- ពិនិត្យមើល និងដោនឡូតព័ត៌មានលម្អិតប្រតិបត្តិការរបស់គណនីជាទម្រង់ PDF
- ពិនិត្យមើល និងដោនឡូតរបាយការណ៍គណនីសម្រាប់រយៈពេលផ្សេងៗ និងជាទម្រង់ផ្សេងៗ
- ដោនឡូតលិខិតបញ្ជាក់បញ្ញើមានកាលកំណត់ដែលបានបើកក្នុងកម្មវិធី ABA Mobile ជាទម្រង់ PDF

### កាត

អ្នកប្រើប្រាស់កម្មវិធី ABA Mobile អាចពិនិត្យមើលកាត ABA រូបវន្ត និងកាតនិម្មិតដែលមានទាំងអស់ រួមមានកាត ATM, VISA, Mastercard និង UnionPay ហើយចូលប្រើប្រាស់មុខងារ និងសេវាកម្មពាក់ព័ន្ធ ដូចខាងក្រោម៖

- ពិនិត្យមើលបញ្ជីកាតដែលមានទាំងអស់
- ពិនិត្យមើលប្រតិបត្តិការពាក់ព័ន្ធនឹងកាតស្ថិតក្រោមគណនីដែលភ្ជាប់ជាមួយ
- បង្កើតកាតនិម្មិត Mastercard ឬ Visa ថ្មី
- ស្នើសុំកាតរូបវន្តថ្មី
- ចាត់ចែង និងគ្រប់គ្រងកម្រិតប្រតិបត្តិការរបស់កាត
- បង្កក ឬលែងបង្កកកាតនៅពេលចាំបាច់
- បើកដំណើរការកាតរូបវន្តដែលបើកថ្មី

### ការផ្ទេរប្រាក់

អ្នកប្រើប្រាស់កម្មវិធី ABA Mobile អាចធ្វើការផ្ទេរប្រាក់ក្នុងស្រុក និងអន្តរជាតិជាច្រើនប្រភេទភ្លាមៗក្នុង 24/7 ៖

- ផ្ទេរប្រាក់ទៅគណនី ABA ណាមួយ
- ផ្ទេរប្រាក់ក្រៅប្រទេសតាម SWIFT

- ទទួល និងផ្ញើប្រាក់ក្រៅប្រទេសតាម RIA
- ទទួល និងផ្ញើប្រាក់ក្រៅប្រទេសតាម MoneyGram
- ផ្ទេរប្រាក់ទៅហ្វីលីពីនតាម DBP
- ផ្ទេរប្រាក់ទៅកាត VISA
- ផ្ទេរប្រាក់ទៅធនាគារក្នុងស្រុក – NCS
- ផ្ទេរប្រាក់ទៅធនាគារក្នុងស្រុក – Bakong
- ផ្ទេរប្រាក់រវាងគណនី ABA និង e-wallets ក្នុងស្រុក ដូចជា៖ Pi Pay, SpeedPay, TrueMoney, Bakong និងមានបន្ថែមទៀតនាពេលអនាគត។

### សេវាទូទាត់

អ្នកប្រើប្រាស់អាចចូលប្រើប្រាស់ និងទូទាត់ទៅកាន់អ្នកផ្តល់សេវាភាគីទីបីជាច្រើនដែលសហការជាដៃគូជាមួយធនាគារ ABA ។ សម្រាប់ការទូទាត់ទាំងនេះ ធនាគារ ABA ដើរតួនាទីត្រឹមតែជាអ្នកសម្របសម្រួលការទូទាត់ជាមួយដៃគូសហប្រតិបត្តិការខាងក្រៅដែលមិនមានទំនាក់ទំនងជាមួយ ABA របស់ ABAតែប៉ុណ្ណោះ ទេ។

អ្នកប្រើប្រាស់អាចចូលប្រើប្រាស់ និងទូទាត់អោយអ្នកផ្តល់សេវាពេញនិយមជាច្រើនតាមប្រភេទដូចខាងក្រោមដោយឥតគិតថ្លៃ៖

- បញ្ចូលលុយទូរស័ព្ទ
- អ៊ីនធឺណិត & ទូរទស្សន៍
- ទឹកភ្លើង
- ការសិក្សា
- កម្សាន្ត
- សេវាសាធារណៈ
- អចលនទ្រព្យ
- ធានារ៉ាប់រង
- ដំណើរ & ទេសចរណ៍
- ថ្លៃសមាជិក & សេវាប្រចាំ
- សប្បុរសធម៌ & ការបរិច្ចាគ
- ពាណិជ្ជកម្ម & ចែកចាយ

### សេវាកម្ម

អ្នកប្រើប្រាស់ ABA Mobile អាចចូលប្រើការផ្តល់សេវាពីដៃគូសហប្រតិបត្តិការខាងក្រៅរបស់ធនាគារ ABA ។ ទោះយ៉ាងណាក៏ដោយ សេវាកម្មទាំងនេះត្រូវបានផ្តល់ជូនក្រោមលក្ខខណ្ឌនៃដៃគូសហប្រតិបត្តិការខាងក្រៅរៀងៗខ្លួន មិនមែននៅក្រោមធនាគារ ABA ទេ។ កិច្ចព្រមព្រៀង និងទំនួលខុសត្រូវក្នុងកិច្ចសន្យាណាមួយនឹងស្ថិតនៅរវាងអ្នកប្រើប្រាស់ ABA Mobile និងដៃគូសហការខាងក្រៅរៀងៗខ្លួន មិនមែននៅក្រោមធនាគារ ABA នោះទេ។ សម្រាប់សេវាកម្មទាំងនេះ ធនាគារ ABA ដើរតួជាអ្នកសម្របសម្រួលការទូទាត់តែប៉ុណ្ណោះ។ សម្រាប់ព័ត៌មានលម្អិត សូមមើលលក្ខខណ្ឌនៃដៃគូសហប្រតិបត្តិការខាងក្រៅរៀងៗខ្លួន។

### គំរូទូទាត់ប្រចាំ

នៅក្នុងផ្នែកនេះ អ្នកប្រើប្រាស់អាច៖

- បង្កើតគំរូថ្មី ដែលត្រូវប្រើញឹកញាប់ ដើម្បីផ្ទេរប្រាក់ទៅអ្នកទទួល និងទូទាត់ជូនអ្នកផ្តល់សេវានានាជាប្រចាំ
- ចូលប្រើគំរូផ្សេងៗដែលបានរក្សាទុក ដើម្បីផ្ទេរប្រាក់ទៅអ្នកទទួល និងទូទាត់ជូនអ្នកផ្តល់សេវានានាជាប្រចាំ

- បង្កើតការផ្ទេរប្រាក់ ឬការទូទាត់ស្វ័យប្រវត្តិ ជាមួយជម្រើសកាលវិភាគជាច្រើន (មួយលើក រាល់សប្តាហ៍ រាល់ខែ រាល់ 3 ខែម្តង រៀងរាល់ 6 ខែម្តង និង រាល់ ឆ្នាំម្តង)
- កំណត់ឲ្យទូទាត់វិក្កយបត្រជូនអគ្គិសនីកម្ពុជាដោយស្វ័យប្រវត្តិ ដែលទឹកប្រាក់នឹងកាត់នៅថ្ងៃចេញវិក្កយបត្រ ចេញពីគណនីរបស់អ្នកដែលអ្នកបានជ្រើសរើស ។

### សេវា E-CASH

សេវា E-Cash ជាសេវាដាច់ដោយឡែកមួយដែលអនុញ្ញាតឲ្យអ្នកប្រើប្រាស់ផ្ញើប្រាក់ទៅ ATM ណាមួយរបស់ធនាគារ ABA ជារូបិយប័ណ្ណប្រាក់ដុល្លារ ឬប្រាក់រៀល ហើយដកប្រាក់ដោយមិនប្រើកាត។

### ស្កែន QR

ជាមួយមុខងារស្កែន QR អ្នកប្រើប្រាស់អាចស្កែនកូដ QR ដើម្បីដំណើរការប្រតិបត្តិការដូចខាងក្រោម៖

ទូទាត់ជាមួយ QR ជាមួយពាណិជ្ជករអនឡាញ ឬរូបវន្តដែលទទួលយកប្រព័ន្ធទូទាត់ ABA PAY, Bakong, Visa QR ឬ Mastercard QR ។

ដាក់ប្រាក់ចូលគណនី ABA តាមម៉ាស៊ីនដាក់ ABA ឬម៉ាស៊ីនដាក់ប្រាក់នានា ។

### កន្លែងទូទាត់ ABA PAY

អ្នកប្រើប្រាស់អាចរកបញ្ជីពាណិជ្ជករនៅកន្លែងដែល ABA PAY អាចប្រើប្រាស់បាន រួមទាំងព័ត៌មានអំពីការបញ្ចុះតម្លៃ ទីតាំង និងព័ត៌មានទំនាក់ទំនង។

### កម្ចីភ្លាមៗតាមទូរស័ព្ទ

អ្នកប្រើប្រាស់ដែលមានគណនីបញ្ញើមានកាលកំណត់ជាមួយធនាគារ ABA អាចស្នើសុំកម្ចី និងទទួលបានប្រាក់ភ្លាមៗចូលក្នុងគណនីរបស់ពួកគេ។

### កម្ចីប្រាក់បៀវត្ស

អ្នកប្រើប្រាស់ អាចស្នើសុំកម្ចីប្រាក់ខែបានយ៉ាងងាយស្រួល អាស្រ័យលើគណនីបើកប្រាក់ខែរបស់ពួកគេ និងធ្វើការទូទាត់សងកម្ចីវិញដោយប្រើ ABA Mobile។

### កម្ចី

ចូលមើលព័ត៌មានលម្អិតអំពីប្រាក់កម្ចី និងមើលកាលវិភាគបង់កម្ចីរបស់អ្នកយ៉ាងងាយស្រួលតាមអេបទូរស័ព្ទ។ ទទួលបានការជូនដំណឹងទាន់ពេលវេលាពាក់ព័ន្ធនឹងការទូទាត់ប្រាក់កម្ចីបន្ទាប់ ការបង់កម្ចីជោគជ័យ និងបរាជ័យ។

សារជូនដំណឹង ABA

អ្នកប្រើប្រាស់ ទទួលបានការជូនដំណឹងភ្លាមៗអំពីប្រតិបត្តិការហិរញ្ញវត្ថុ ឬចរន្តទឹកប្រាក់ នៅក្រោមគណនី ឬកាតរបស់ខ្លួន។ សារជូនដំណឹង លេចឡើងជាផ្ទាំងលើអេក្រង់ភ្លាមៗបន្ទាប់ពីប្រតិបត្តិការនីមួយៗត្រូវបានធ្វើឡើង។

### ទីតាំង ABA

អ្នកប្រើប្រាស់អាចចូលប្រើប្រាស់ផែនទីអន្តរកម្មដែលអាចរកឃើញទីតាំងសាខា ABA ម៉ាស៊ីន ATM និងម៉ាស៊ីនដាក់ប្រាក់ទាំងអស់។

### ទាក់ទងយើងខ្ញុំ

ក្នុងមុខងារនេះ អ្នកប្រើប្រាស់អាចទាក់ទងសេវាអតិថិជនរបស់ធនាគារ ABA 24/7 តាមរយៈការផ្តេបញ្ចេញមតិ កម្មវិធីផ្ញើសារហ្វេសប៊ុក ឬតេមទៅធនាគារ ។

### អត្រាប្តូរប្រាក់

ផ្នែកនេះបង្ហាញអត្រាប្តូរប្រាក់សម្រាប់រូបិយប័ណ្ណពេញនិយមទាំងអស់នៅក្នុងកម្ពុជា។ផ្នែកនេះក៏រួមបញ្ចូលម៉ាស៊ីនគិតលេខរូបិយប័ណ្ណដែលអាចពិនិត្យមើលអត្រាប្តូរប្រាក់សម្រាប់ចំនួនទឹកប្រាក់ណាមួយភ្លាមៗ។

### ផ្ទាំងវិចិត្រ

បង្កើនផលិតភាព និងបទពិសោធក្នុងការប្រើសេវាធនាគាររបស់អ្នក ដោយដាក់ផ្ទាំងវិចិត្រលើអេក្រង់ដើម ABA Mobile។ ផ្ទាំងវិចិត្រទាំងនេះ ផ្តល់នូវភាពងាយស្រួល និងការចូលប្រើមុខងារផ្សេងៗបានរហ័ស ដូចជា ABA KHQR, ពិនិត្យសមតុល្យគណនី និងហាងឆេងប្តូរប្រាក់ប្រចាំថ្ងៃ។

### កែអេក្រង់ដើម

យើងខ្ញុំយល់ច្បាស់ថា ការប្រើប្រាស់ឲ្យមានលក្ខណៈផ្ទាល់ខ្លួនគឺសំខាន់។ ដូច្នេះ អ្នកប្រើប្រាស់អាចកែប្រែអេក្រង់ដើម ABA Mobile តាមការពេញចិត្ត ឬតាមអារម្មណ៍របស់ពួកគេ។ មុខងារទាំងនោះមានដូចជា៖

- មុខងារ រៀបចំប៊ូតុង សម្រាប់ការចូលទៅកាន់សេវាកម្មដែលប្រើញឹកញាប់បានលឿនរហ័ស
- ការកំណត់រូបភាពផ្ទៃខាងក្រោយ និងប៊ូតុងឲ្យមានលក្ខណៈផ្ទាល់ខ្លួន
- ការកែទំហំអក្សរតូច ឬធំ ដើម្បីងាយស្រួលមើល
- ប្តូរទៅមករវាងផ្ទៃងងឹត និងភ្លឺ តាមការពេញចិត្ត

### ដំណឹង និងប្រូម៉ូសិន

ទទួលបានដំណឹង និងប្រូម៉ូសិនថ្មីៗ ដែលផ្តល់ជូនដោយធនាគារ ABA។

### ការស្វែងរកថ្មីៗ

ស្វែងរកមុខងារថ្មីៗ ស្វែងយល់ពីរបៀបប្រើប្រាស់ ABA Mobile ឲ្យស្ទាត់ជំនាញ និងទទួលបានចំណេះដឹងហិរញ្ញវត្ថុដ៏មានប្រយោជន៍ ដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រើសេវាធនាគាររបស់អ្នក។

### ប្រូហ្វាលអ្នកប្រើប្រាស់

អ្នកប្រើប្រាស់អាចចូលមើល និងអាប់ដេតរូបប្រូហ្វាល និងព័ត៌មានផ្ទាល់ខ្លួន ដើម្បីធានាថាព័ត៌មានទាំងនោះគឺនៅតែត្រឹមត្រូវ និងពិតប្រាកដ។

### សុវត្ថិភាព

អ្នកប្រើប្រាស់មានភាពបត់បែនក្នុងការកែប្រែ ផ្នែកការកំណត់សុវត្ថិភាព របស់ ABA Mobile តាមតម្រូវការផ្ទាល់ខ្លួន ដែលអាចមានដូចជា៖

- បើកការផ្ទៀងផ្ទាត់ពីរជំហានជាមួយ FacePass Secure
- អាប់ដេតព័ត៌មានទំនាក់ទំនង ដូចជាលេខទូរស័ព្ទ
- ប្តូរលេខសម្ងាត់ (PIN) និងមុខងារជាច្រើនទៀត

# ឧបសម្ព័ន្ធ ខ

បញ្ជីកម្រិតប្រតិបត្តិការដែលមាននៅលើ ABA Mobile គិតត្រឹមខែតុលា ឆ្នាំ 2023

### សេវាផ្ទេរប្រាក់៖

| ប្រភេទសេវាកម្ម | ទឹកប្រាក់ អតិបរមា/ប្រតិបត្តិការ | ទឹកប្រាក់ អតិបរមា/ថ្ងៃ | ទឹកប្រាក់ អតិបរមា/ខែ | ចំនួន អតិបរមា/ថ្ងៃ |
|---|---|---|---|---|
| ផ្ទេរប្រាក់ទៅគណនី ABA ផ្ទាល់ខ្លួន | Unlimited | Unlimited | - | 20 |
| ផ្ទេរប្រាក់ទៅគណនី ABA ផ្ទាល់ខ្លួន | $500,000.00 | $500,000.00 | - | 20 |
| ផ្ទេរប្រាក់ទៅគណនី ABA ណាមួយ | $100,000.00 | $100,000.00 | - | - |
| ផ្ទេរប្រាក់ក្រៅប្រទេស SWIFT | $100,000.00 | $100,000.00 | - | - |
| សេវាផ្ទេរប្រាក់អន្តរជាតិ – Ria | $9,999.00 | $9,999.00 | $9,999.00 | - |
| សេវាផ្ទេរប្រាក់អន្តរជាតិ – MoneyGram | $9,900.00 | $9,900.00 | - | - |
| ផ្ទេរប្រាក់ទៅហ្វីលីពីនតាម – DBP | $9,900.00 | $9,900.00 | - | - |
| ផ្ទេរប្រាក់ទៅធនាគារក្នុងស្រុក – NCS | $100,000.00 | $100,000.00 | - | - |

| ប្រភេទសេវាកម្ម | ទឹកប្រាក់អតិបរមា/ប្រតិបត្តិការ | ទឹកប្រាក់អតិបរមា/ថ្ងៃ | ទឹកប្រាក់អតិបរមា/ខែ | ចំនួនអតិបរមា/ថ្ងៃ |
|---|---|---|---|---|
| ផ្ទេរប្រាក់ទៅធនាគារក្នុងស្រុក – Bakong | 50,000.00 | $50,000.00 | - | - |
| ផ្ទេរប្រាក់ទៅ TrueMoney | $1,000.00 | $1,000.00 | $5,000.00 | - |
| ផ្ទេរប្រាក់ទៅ Pi Pay | $2,500.00 | $2,500.00 | $5,000.00 | - |
| ផ្ទេរប្រាក់ទៅ Wing | $10,000.00 | $10,000.00 | - | - |
| ផ្ទេរប្រាក់ទៅ KESS | $2,500.00 | $2,500.00 | $5,000.00 | - |
| ផ្ទេរប្រាក់ទៅ Bakong Wallet | $1,000.00 | $2,500.00 | $20,000.00 | - |
| ផ្ទេរប្រាក់ទៅ VISA Card | $2,500.00 | $5,000.00 | $20,000.00 | 10 |
| ផ្ទេរប្រាក់ទៅ Mastercard | $2,500.00 | $5,000.00 | $20,000.00 | 10 |
| ផ្ទេរប្រាក់ទៅ UnionPay Card | $2,500.00 | $5,000.00 | $10,000.00 | 10 |
| ABA KHQR - ពាណិជ្ជករ | $5,000.00 | $5,000.00 | - | - |
| ABA KHQR - ផ្ទេរប្រាក់ | $2,500.00 | $5,000.00 | - | - |
| ABA Pay | $100,000.00 | | | |
| ABA Pay CoF | $100.00 | $500.00 | - | 10 |
| ប្រើស្កេនផ្ទៃមុខសម្រាប់ការទូទាត់និងផ្ទេរប្រាក់ | $1,000.00 | - | - | - |
| E-Cash | $1,000.00 | $3,000.00 | - | - |

## សេវាទូទាត់ប្រាក់៖

| ប្រភេទសេវាកម្ម | ទឹកប្រាក់អតិបរមា/ប្រតិបត្តិការ | ទឹកប្រាក់អតិបរមា/ថ្ងៃ | ចំនួនអតិបរមា/ថ្ងៃ |
|---|---|---|---|
| អគ្គិសនីកម្ពុជា | $100,000.00 | $100,000.00 | 15 |
| ទឹកភ្លើង និង សំរាម | $100,000.00 | $100,000.00 | - |
| សេវាសាធារណៈ | $100,000.00 | $100,000.00 | - |
| ពាណិជ្ជកម្ម និងចែកចាយ | $100,000.00 | $100,000.00 | - |
| ធានារ៉ាប់រង | $25,000.00 | $25,000.00 | - |
| អចលនទ្រព្យ | $50,000.00 | $50,000.00 | - |
| ការសិក្សា | $50,000.00 | $50,000.00 | - |
| ផ្សេងៗ | $5,000.00 | $5,000.00 | - |

*-ចប់-*

ABA
BANK

NATIONAL BANK
OF CANADA GROUP

អគារលេខ 141, 146, 148 និង 148 អា បេ សេ ដេ មហាវិថីព្រះសីហនុ និង
អគារលេខ 15 និង 153 អា បេ សេ ផ្លូវ 278 សង្កាត់បឹងកេងកងទី 1
ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ប្រព័ន្ធទូរស័ព្ទឥតគិតថ្លៃ 1 800 203 203 | ទូរសារ: (+855) 23 216 333
info@ababank.com | www.ababank.com